# ពោធិព្រឹក្ស

លេខ ៦៥ ខែ កញ្ញា គ.ស.២០១៩ N° 65 Mois de septembre 2019

Pothiproeuk



សម្ពោធន៍ កុដិសម្ភារៈ កាលពី ថ្ងៃ១៧ កុម្ភៈ ២០១៩

*L'Inauguration du magasin de stockage rénové*
*Le 17 février 2019.*

ព្រឹត្តិប័ត្រ សមាគមឧបត្ថម្ភពុទ្ធសាសនាខ្មែរ វត្តពោធិវង្ស
**BULLETIN DE L'ASSOCIATION POUR LE SOUTIEN DU BOUDDHISME KHMER**

# SOMMAIRE


| N° | Titre | Pages |
|---|---|---|
| 1 | Couverture | |
| 2 | | |
| 3 | Sommaire | 3 |
| 4 | ខ្មែរត្រូវធ្វើយ៉ាងម៉េច? Editorial du Vénérable NGIN Phén | 4-7 |
| 5 | Nouvelles :<br>សុន្ទរកថា Discours ឃិន សុផល KHIN Sophâl<br>1-មាឃបូជា និងសម្ពោធន៍កុដិសម្ភារៈ Meak Bochea et Inauguration du magasin<br>2-ចូលឆ្នាំ កុរ Le nouvel an Khmer<br>3- Photos de souvenir de nouvel an | 8-10<br>11-13<br>14-15 |
| 6 | Informations :<br>- Reportage រ៉ាវី ឃិន Ravie KHIN<br>1) A la mémoire du Dr Beat RICHNER<br>2) L'initiation à la Méditation<br>- Coupure de presses : des Félicitations ទេព កុលវុធ TEP Kolavudh<br>1) Trophée de Cuisine 2018<br>2) Trophée de Jiu -Jitsu 2018<br>- Deuxième journée culturelle Khmer ដារ៉ាវី ប៉ុន Daravie PON | 16-17<br>18-24<br>25-27<br>28-31 |
| 7 | Textes :<br>អានិសង្ស សង់សាលា ទេព ប៊ុនថាក់ណា TEP Bounthakna<br>ABHIṆHA PACCAVEKKHAṆA អភិណ្ហបច្ចវេក្ខណ (ត) ង្វី ហុក NGY Hok<br>អរិយបុគ្គល Ariya puggala. ឈិម សាវិត CHHIM Savit | 32-34<br>35-43<br>44-46 |
| 8 | Poèmes :<br>មិត្ត នឹង អមិត្ត នេត្រ សេដ្ឋា NET Sétha<br>HYMNE à la Vie au Bonheur Mme le Docteur Péou ROUZOTTE | 47<br>48 |
| 9 | Divers :<br>ការសិក្សាអត្ថបទវិជ្ជា ឃីង ហុកដី KHING Hocdy<br>សប្បាយមកវត្តពោធិវង្ស ទេព ប៊ុនថាក់ណា TEP Bounthakna<br>សេចក្ដីជូន ដំណឹង L'information : Bulletin<br>Composition du comité | 49-54<br>55-59<br>60 |

# ខ្មែរត្រូវធ្វើយ៉ាងម៉េច ?

*ខ្មែរជាជាតិមួយ មានពូជអម្បូរខ្លាំងពូកែមានវប្បធម៌ខ្ពង់ខ្ពស់ មានកិត្តិយស ល្បីល្បាញ ។ ខ្មែរយើងមានសេចក្តីចំរើន លូតលាស់មុនគេ នៅអាស៊ីអាគ្នេយ៍ (មុនសៀមមុនយួន) មានប្រវត្តិសាស្ត្រ និង ប្រាសាទសីលា ជាភស្តុតាងស្រាប់។*

*ក្រោយសម័យមហានគរ ខ្មែរចុះអន់ថយជាលំដាប់ ពេលខ្លះធ្លាក់ខ្លួនជាចំណុះ សៀម ពេលខ្លះធ្លាក់ខ្លួនជាចំណុះយួន ហើយមានពេលខ្លះទៀត ទាំងសៀម ទាំងយួន ព្រួតគ្នាត្រួតត្រាខ្មែររហូតដល់បារាំងចូលមកគ្រប់គ្រងទើបចប់ ។ រឿងរ៉ាវទាំងអស់នេះ ខ្មែរយើង ត្រូវសិក្សាឲ្យច្បាស់លាស់ ឲ្យស៊ីជម្រៅ ឲ្យម៉ត់ចត់សព្វគ្រប់ទុកជាមេរៀន ដើម្បីដឹកនាំជាតិកុំឲ្យដើរខុសផ្លូវតទៅទៀត ។*

*ក្រោយពីរំដោះខ្លួន រួចផុតពីអាណានិគមបារាំង ខ្មែរយើងបានឡើងឋានៈជាប្រទេសឯករាជ្យ ជាកោះសន្តិភាព បានសុខសប្បាយមិនវែងឆ្ងាយយូរប៉ុន្មានផង ក៏ចាប់ដើរផ្ទៀង បើកដៃឲ្យយួនកុម្មុយនិស្តដើរចូលស្រុកខ្មែរ តាមផ្លូវលំហូជីមិញ វាយយួនខាងត្បូង ជាហេតុធ្វើឲ្យខ្មែរក្លាយជាភ្នក់ភ្លើងសង្គ្រាម។ បន្ទាប់មក ប្រទេសខ្មែរប្រែជា សាធារណរដ្ឋ ដោយរបប* ***លន់ នល់*** *ហើយក៏ធ្លាក់ចុះក្នុងរណ្តៅនរកនៃខ្មែរក្រហម* ***ប៉ុល ពត*** *អស់ ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ ទើបងើបរួច ។ រឿងរ៉ាវទាំងអស់នេះ សុទ្ធតែជា មេរៀន ដ៏សំខាន់ៗ ដែលខ្មែរយើង ត្រូវសិក្សា ដើម្បី កុំឲ្យដើរខុសឆ្គង ដូចមុនទៀត ។*

*ថ្ងៃ ៧ មករា ជាថ្ងៃរំដោះ ? ឬ ជាថ្ងៃឈ្លានពាន ?*

*គិតឲ្យជ្រៅ គិតឲ្យម៉ត់ចត់ គិតឲ្យសព្វគ្រប់មើល! បើពិតជាថ្ងៃរំដោះមែន ម៉េចក៏រំដោះ ហើយ មិនត្រឡប់ទៅវិញ ម៉េចក៏យួនឲ្យខ្មែរធ្វើ សន្ធិសញ្ញា ធ្វើកិច្ចព្រមព្រៀង ដែលជាបន្ទុកមកលើខ្មែរច្រើនម៉្លេះ ? ម៉េចក៏បញ្ជូល អាណិកជនយួន ចូលមកស្រុកខ្មែរ បង្កើតជា និគមយួន ច្រើនម៉្លេះ? ម៉េចក៏សុំសម្បទានដី ច្រើនម៉្លេះ ? ម៉េចក៏ធ្វើវិមានកម្ពុជា វៀតណាម ច្រើនម៉្លេះ ? ម៉េចក៏ធ្វើវិមានជ័យជំនះ ? ម៉េចក៏បង្កើត តំបន់ត្រីកោណ តើដើម្បីនរណា ? ខ្មែរជួយយួន ម៉េចក៏មិនធ្វើវិមាន វៀតណាមកម្ពុជាផង?*

សេចក្តីសម្រេចនៃកិច្ចព្រមព្រៀងក្រុងបារីស ២៣ តុលា ១៩៩១ បានលុប សន្ធិសញ្ញាណា ដែលខូចផលប្រយោជន៍ខ្មែរចោលអស់ហើយម៉េចក៏ **ហ៊ុន សែន** ធ្វើបន្ថែមឡើងវិញ ទាំងអស់នេះ ខ្មែរត្រូវតែរៀនសូត្រឲ្យច្បាស់លាស់ ម៉ត់ចត់ពិតប្រាកដ ។

ទន្ទឹមគ្នានឹងយួន ចិនក៏បានហូរចូលមកកាន់ស្រុកខ្មែរកាន់តែច្រើនឡើងៗ ក្រុងកំពង់សោម មិនយូរទេ អាចនឹងក្លាយជាទីក្រុងចិន ខេត្តកោះកុង កំពង់ផែទឹកជ្រៅ ចិនកំពុងកសាង អាកាសយានស្ថានដ៏ធំ ប្រាប់ថា សំរាប់ទេសចរណ៍ ដែលប្រសិទ្ធិនាមថា តារាសាគរ ប៉ុន្តែ បើមិនមាននរណាទប់ទេចិននឹងប្រើជាកន្លែងដឹកជញ្ជូនកងទ័ព ដែលអាចនឹងមានកងទ័ព ដើងទឹក នៅមាត់សមុទ្ររាម ជាត្រើះ ។ ចិនមិនមែនចូលនៅស្រុកខ្មែរ តែប៉ែកជួរខាងលិចរហូតដល់ ឧត្តរមានជ័យទេ តែចិនមាននៅពាសពេញប្រទេស ភ្នំពេញ ស្វាយរៀង តាកែវ ។ល។ គេថាចិន បានសាងទីក្រុងមួយដ៏ធំ ក្នុងខេត្តស្ទឹងត្រែង ពលរដ្ឋខ្មែរគ្នាឯងមិនទាំងដឹងផង ដឹងតែគ្នាគេប៉ុន្មាននាក់ ហាមចូលមើល...។ រឿងនេះខ្មែរត្រូវតែសិក្សាឲ្យច្បាស់លាស់ ពិតប្រាកដ ។

សម្បត្តិធម្មជាតិខ្មែរ រ៉ែ ព្រៃឈើ ។ល។ វិនាសជិតអស់ហើយ ដោយសារតែ យួន និង ចិន ។ ខ្មែរម្ចាស់ស្រុក គ្មានបានផលប្រយោជន៍អ្វី ជាធំដុំទេ ។ ដោយសារ តែគេ សម្បទានដី រាប់លានហិកតាឲ្យ យួន ចិន ដីរាស្ត្រខ្មែរនៅក្បែរនោះ ត្រូវគេកាត់ជ្រៀកយកដោយមិនត្រឹមត្រូវ មិនសមរម្យ ខ្មែរយំស្រែកតវ៉ាយ៉ាងណា ក៏គេមិនសូវរវល់ដែរ តើឲ្យខ្មែរម្ចាស់ស្រុករស់នៅយ៉ាងម៉េច ? ទ្រាំដល់ណាទៀត ?

ប្រជាជនខ្មែរ អ្នកមានទ្រព្យស្តុកស្តម្ភ មានចំនួនតិចតួចណាស់អ្នកមានទ្រព្យធូរជារល្មមគួរសម ក៏មានមិនច្រើនដែរ ឯអ្នកមានទ្រព្យគ្រាន់តែគ្រប់និង អ្នកខ្វះខាត អ្នកជំពាក់បំណុលគេ មានចំនួនច្រើនលើសលប់ ។ គម្លាតជីវភាព ឆ្ងាយពីគ្នា ដូចមេឃនិង ដី ។ អ្នកមាន រស់នៅដូចទេវតា អ្នកក្រ ទុក្ខវេទនា ដូចប្រេតនរក ។ សព្វថ្ងៃ ប្រទេសកម្ពុជា ជំពាក់បំណុលគេជាង ១១ម៉ឺនលានដុល្លារហើយ គ្រាន់តែប្រទេសចិន ប្រហែល៥ពាន់លានដុល្លារ ។ ផលិតផលកសិកម្ម ដែលខ្មែរធ្វើបានច្រើន គ្មានទីផ្សារ របស់ណាដែលខ្មែរ ធ្វើមិនទាន់បានគ្រប់គ្រាន់ ត្រូវចំណាយ លុយរាប់ពាន់លាន ទិញចូលពីថៃ យួន និង ចិន របស់ខ្វះទៀត ខ្មែរធ្វើបានដែរ តែលក់ខាតទុន មិនរួចខ្លួន ជំពាក់បំណុលធនាគារ ត្រូវគេរឹបអូសយកដីធ្លី ផ្ទះសម្បែង ។ ហេតុនេះហើយ

ដែលប្រជាជនខ្មែរ រាប់លាននាក់ ត្រូវបង្ខំចិត្ត ចេញចាកផ្ទះ ព្រាត់ ប្រពន្ធ កូន ចៅ ទៅធ្វើខ្ញុំកញ្ជះគេ នៅថៃ កូរ៉េ ម៉ាឡេស៊ី ជប៉ុន ។ល។ ដើម្បីរកប្រាក់សងគេ និង ដើម្បីរស់ ។ ឯប្រជាជន រស់នៅក្នុងស្រុកវិញ ក្រៅពីក្រីក្រ ទុក្ខលំបាកហើយមិនមាន សិទ្ធិ សេរីភាព គ្រប់គ្រាន់ទេ សូម្បីរឿងកំប៉ិកកំប៉ុកឬ ស៊ីនំបញ្ចុក ក៏ត្រូវគេរឹតត្បិតតាមដានដែរ ។ **គង់ រ៉ៃយ៉ា និង សួង នាគពន្ធ័** គ្រាន់តែធ្វើបុណ្យ **កែម ឡី** ត្រូវគេចោទដោយអយុត្តិធម៌ ចាប់យកទៅដាក់គុក គុកស្មោគគ្រោក ចង្អៀតណែន ពេញហៀរហើយ គ្រាន់តែជាប់គុក ក៏មិនមានភាពស្មើគ្នាដែរ ។ បន្ថែម លើនេះទៀត ដោយរបប ហ៊ុន សែន បំផ្លាញសិទ្ធិ សេរីភាព និង ប្រជាធិបតេយ្យ សហភាពអឺរ៉ុប និង សហរដ្ឋអាមេរិក កំពុងគិតបញ្ឈប់ ការអនុគ្រោះពន្ធ **E.B.A G.S.P** និង ដាក់ទណ្ឌកម្ម បង្កកទ្រព្យសម្បត្តិ មេផ្តាច់ការ និង ក្រុមទុច្ចរិត ពុករលួយផង។

សូម្បី កម្ពុជា មានសភាពការណ៍ យ៉ាងដូចនេះហើយ ប្រជាជនខ្មែរ នៅតែមិនទាន់ភ្ញាក់រលឹក មួយចំនួន កំពុងតែសប្បាយដូចតទៅនេះ ៖

១. សប្បាយនឹង រកស៊ីខុសច្បាប់ ។

២. សប្បាយនឹង ស្រា ស្រី ល្បែងភ្នាល់ គ្រឿងញៀន ។

៣. សប្បាយនឹង ធ្វើបុណ្យទាន ខ្វះវិចារណញ្ញាណ ចង់ឡើងស្ថានសួគ៌។

៤. សប្បាយនឹង សក្តិយស ឯកឧត្តម ជំទាវ ឧកញ៉ា។

៥. សប្បាយនឹង សម្តេចសង្ឃ រាជាគណៈ មេគណ អនុគណ ចៅអធិការ និង ធម្មាចារ្យ។

៦. សប្បាយនឹង ឈ្លោះគ្នា សម្លាប់គ្នា ដណ្តើមអំណាច ពឹងបរទេសជួយ។

៧. សប្បាយនឹង កុហក បោកប្រាស់ បំពេរគ្នា ឲ្យលង់ ឲ្យញៀន ឲ្យពុល យល់ខុស ជឿផ្តេសផ្តាស។

ចំណែកខ្មែរ មួយចំនួនទៀត ភ្ញាក់រលឹក ត្រូវគេសម្លុត បៀតបៀន ធ្វើទុក្ខ ជាប់គុកប្រវាក់ រត់ចោលស្រុក ឬ ត្រូវគេសម្លាប់ចោល ក៏មាន។ បើខ្មែរមិនភ្ញាក់រលឹក ពិសេសថ្នាក់ដឹកនាំ

នៅតែប្រព្រឹត្តដូចនេះ មិនយូរទេ ខ្មែរ និង ទៅជាខ្ញុំកញ្ជះ ចិន យួន រលាយប្រទេសជាតិ ដូចចម្ប៉ា ពិតប្រាកដ។ ប្រហែស បាត់ ប្រយ័ត្នគង់។

ខ្ញុំព្រះករុណា អាត្មា សង្ឃឹម និង ជឿជាក់ថា មាគ៌ាមានតែ១ទេ គឺខ្មែរភ្ញាក់រលឹកឈប់ឈ្លោះគ្នា ឈប់បៀតបៀន កាប់សម្លាប់គ្នា ខ្មែររួបរួមគ្នា ខ្មែរស្មោះត្រង់គ្នា ខ្មែរយកប្រយោជន៍ជាតិជាធំ ចេះសង្គ្រោះ អនុគ្រោះគ្នា អត់ឱនគ្នា មានមេត្តា ករុណា រាប់អានគ្នា មានសមធម៌ យុត្តិធម៌ ។ល។ បើកឱកាសឲ្យមាន សិទ្ធិ សេរីភាព ប្រជាធិបតេយ្យ យករាស្ត្រជាធំ ធំពិតប្រាកដ រាស្ត្រចង់បានអ្វី ធ្វើតាមបំណងរាស្ត្រ មិនមែនធ្វើតាមចិត្តខ្លួន ហើយឆ្លើយថារាស្ត្រទេ។ បើខ្មែរ ព្រមព្រៀងគ្នា ប្រព្រឹត្តដូចនេះ ខ្មែរនឹងបានសុខសប្បាយ ចំរើន ថ្កុំថ្កើង រុងរឿងវិញពិតពុំខាន។

សូមគុណព្រះរតនត្រ័យ និង វត្ថុសក្តិសិទ្ធិ ក្នុងលោក ជួយឧបត្ថម្ភ គាំទ្រខ្មែរ ដើម្បីបានសម្រេចតាមបំណងនេះ៕

ថ្ងៃព្រហស្បតិ៍ ១៥ សីហា ២០១៩

**ភិក្ខុ ងិន ភេន** ឥន្ទប្បញ្ញោ

# សុន្ទរកថា ថ្លែងក្នុងឱកាសបុណ្យ មាឃបូជា

*ថ្ងៃអាទិត្យ ទី១៧ ខែកុម្ភៈ ឆ្នាំ២០១៩*

*សូមថ្វាយបង្គំព្រះអង្គគ្រូជិន គេន ប្រធានសមាគមឧបត្ថម្ភពុទ្ធសាសនាខ្មែរ វត្តពោធិវង្ស*

*សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ*

*សូមថ្វាយបង្គំ ព្រះរាជវង្សានុវង្ស ក្សត្រាក្សត្រិយ*

*សូមជំរាប លោកស្រី លោកប្រុស សប្បុរសជន*

*និងពុទ្ធបរិស័ទទាំងអស់នៅទីនេះ សូមព្រះអង្គជ្រាប សូមជ្រាប ។*

*ថ្ងៃនេះ តាងនាមគណៈកម្មាធិការបុណ្យ និងក្នុងនាមខ្ញុំព្រះករុណា ខ្ញុំបាទ ជាអគ្គលេខាធិការសមាគម សូម ស្វាគមន៍ និងសូមថ្លែងអំណរគុណ ដល់អស់លោក លោកស្រី ដែលអញ្ជើញមក ចូលរួមបានកុះករ ដើម្បីរំលឹកគុណព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គ ទ្រង់ប្រកាសបង្កើត ព្រះពុទ្ធសាសនា កាលពី ៥៨៨ ឆ្នាំ មុនគ្រិស្តសករាជ បន្ទាប់ពីការត្រាស់ដឹងរបស់ព្រះអង្គ ៩ខែគត់ ក្នុងចំណោមព្រះសង្ឃ ១២៥០ អង្គ ដែល និមន្តមកព្រមៗគ្នា ជាលើកដំបូង ដោយមិនបាននិមន្តព្រាងទុក។*

*នាថ្ងៃទី ១៥កើត ខែមាឃ ឆ្នាំម្សាញ់ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រកាសនូវ គោលការណ៍ ១១ប្រការ ជាភាសាបាលីថា "ឱវាទបាដិមោក្ខ" សម្រាប់ឲ្យសមាជិកមហាសន្និបាតទាំងអស់កាន់យកជាមាគ៌ាជីវិត និងសម្រាប់យកទៅផ្សព្វផ្សាយជូនដល់ជនដទៃទៀត ឲ្យយកមកសិក្សា ឲ្យបានយល់ពីព្រះពុទ្ធសាសនា និងយក មកអនុវត្តពីជំនាន់មួយ ទៅជំនាន់មួយ ហើយទៅជំនាន់មួយទៀត។*

*ភិក្ខុសង្ឃ និងពុទ្ធបរិស័ទទាំងឡាយមានសេចក្តីតក់ស្លុតយ៉ាងខ្លាំង ដោយព្រះពុទ្ធជាបរមគ្រូទ្រង់ប្រកាសថា*

*ព្រះអង្គនឹងត្រូវយាងចូលបរិនិព្វាន ក្នុង ៣ខែខាងមុខនេះ ហើយ ។*

*ខ្លឹមសារសំខាន់ក្នុងបុណ្យមាឃបូជានេះ គឺការទទួលយកឱវាទ របស់ព្រះអង្គមកគោរពប្រតិបត្តិរឹតចំណង សាមគ្គី ស្រឡាញ់រាប់អានគ្នា រួមរស់ដោយសុខសន្តិភាព ក្នុងនាមជាពុទ្ធសាសនិកជន និងមនុស្សជាតិទូទៅ។*

ហេតុដូចនេះហើយ វេលាម៉ោង ១៣បន្តិចទៀតនេះ យើងខ្ញុំព្រះករុណាទាំងអស់គ្នា ជាមួយនឹងព្រះសង្ឃ ធ្វើបុណ្យសម្ពោធឆ្លង និងកាត់ខ្សែបូរបើកទ្វារ «រោងថ្មី» ដែលទើបនឹងសង់ ចប់ជាស្ថាពរនៅក្នុងខែនេះ ។

នេះ ជាកញ្ចក់ឆ្លុះបញ្ចាំងជាក់ច្បាស់ពីសទ្ធាជ្រះថ្លាទឹកចិត្តបរិសុទ្ធ របស់គណៈកម្មការគ្រប់ជំនាន់ របស់ពុទ្ធ បរិស័ទ របស់សប្បុរសជន ជួយឧបត្ថម្ភពុទ្ធសាសនា ឲ្យស្គាល់តែភាពរុងរឿង និងចំរើនលូតលាស់ ជានិរន្តរ ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះលោកស្រី លឹម កែវ វណ្ណា (Lim Keo Vanna) និង ឧបាសិកា Lim Sauv Thung ដែលមានសទ្ធាជ្រះថ្លាជួយឧបត្ថម្ភ កំរាលឈើ និងកំរាលឥដ្ឋដល់ រោងថ្មីនេះតម្លៃ ៤ ០០០ អឺរ៉ូ ។

រោងបុណ្យនេះ កសាងឡើង ក្នុងដើមខែកញ្ញា ឆ្នាំ ២០១៧ តាមលំនាំ សំណង់ចាស់ពីមុនដោយបានសុំច្បាប់អនុញ្ញាត និង ទទួលស្គាល់ពី សាលាសង្កាត់ (Mairie de Champs sur Marne) ។

ដើមឡើយ រោងនេះមានបន្ទប់មួយសម្រាប់ប្រតិបត្តិសមាធិ និងបន្ទប់មួយទៀត ជាកុដិ របស់ព្រះអង្គផល មុននឹងទទួលអនិច្ចធម្ម។ រោងទ្រុឌទ្រោមនេះសើមជោគជាំ ស្រក់ទឹកចូលក្នុងបន្ទប់ រាល់ពេលធ្លាក់ភ្លៀង ដោយសារតែដំបូលចាស់ពុកផុយពេក។ បន្ទាប់ពីការប្រជុំ ពិភាក្សាពិចារណាមកគណកម្មការ និងព្រះ សង្ឃ ក៏បានអនុម័តសម្រេច កសាងរោងជាថ្មី ។

ព្រះអង្គគ្រូ ងិន គេន លោក ហេង គីម និង ខ្ញុំព្រះករុណា ខ្ញុំបាទ សម្រេចចិត្តទទួលខុសត្រូវ និងសម្រួលកិច្ចការ សាងសង់ផ្ទាល់ ដោយសំចៃ ផ្ចិតផ្ចង់ជៀសវាង កុំឲ្យអស់ថវិកាច្រើន ដោយមិនព្រមហៅ សហគ្រាស (entreprise) ពីក្រៅ មកសង់ព្រោះត្រូវចំណាយថវិកាច្រើនហួសពេក ។

មកទល់និងពេលនេះ ប្រាក់ចំណាយ ទៅលើជាងសំណង់មួយចំនួន ទៅលើសម្ភារៈសំណង់ សរុបទៅចំណាយអស់ចំនួន ៦៨ ពាន់ អឺរ៉ូ (68. 000 euro )។

សូមថ្លែងអំណរគុណដ៏មហោឡារិកចំពោះលោក ហេង គឹម ដែលមានសទ្ធាជ្រះថ្លា ដោយក្តីរីករាយស្មោះត្រង់ មកលើវត្តពោធិវង្ស ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ព្រមទាំងថវិកាផ្ទាល់ របស់លោកទៀតផង។ លោកតែង ណែនាំ ពន្យល់យ៉ាងម៉ត់ចត់ទៅកូនជាង ដោយសំដី អាណិតស្រឡាញ់ផ្អែមពិរោះ ។

*ព្រះសង្ឃនិងបងប្អូនខ្មែរមួយចំនួនទៀតបានមកជួយដោយសុទ្ធចិត្តជ្រះថ្លា ស្មោះស្ម័គ្រដូចជា លោក លាង សុខគ្រី - លោករស្មី - លោកដារីត - លោកឃិន ហ៊ីម - លោកពល សំអឿន - លោកអ៊ឹង ពោយៀង - លោកនៅ ហូ - លោកសេរីវុឌ្ឍន៍ - លោកតាហួន - លោកមនោ - លោកគយ សារេត - លោកចេង - លោកហេង - លោកសៀន និងពុទ្ធបរិស័ទមួយចំនួនដែល ខ្ញុំព្រះករុណា ខ្ញុំបាទមិនបានចាំឈ្មោះអស់ សូមមេត្តាអភ័យទោសឲ្យទានផង។*

*ខ្ញុំព្រះករុណា ខ្ញុំបាទ សូមក្រាបថ្វាយបង្គំព្រះអង្គគ្រូ ផិន គេន តាំងពីព្រះអង្គមកគង់នៅវត្តពោធិវង្សដោយ បច្ច័យព្រះអង្គផ្ទាល់ ជួយគ្រប់គ្រងវត្ត រៀបចំ ពិនិត្យពិច័យគ្រប់បែបយ៉ាង ដើម្បីឲ្យបានសុខសប្បាយ មានសន្តិភាព ជ្រះថ្លាជូនចំពោះពុទ្ធបរិស័ទ និងសប្បុរសជនដែល នឹងអញ្ជើញមកធ្វើពិធីបុណ្យរៀងៗខ្លួន និង*

*ពិធីបុណ្យរួមជាមួយនឹងវត្ត ។*

*ព្រះអង្គគ្រូ លោកបានជួយដោះស្រាយបញ្ហាខ្មែរក្រីក្រទាំងក្មេង ទាំងចាស់ ក្នុងស្រុក ឬក្រៅស្រុក ព្រមទាំង សមាគមខ្មែរខ្លះទៀត ដោយបច្ច័យព្រះអង្គផ្ទាល់។ ព្រះអង្គតែងតែអំពាវនាវឲ្យជួយរំដោះទុក្ខដល់ប្រទេស ណាដែលប្រជាជនជួបប្រទះនឹងគ្រោះថ្នាក់ដ៏ធ្ងន់ ព្រះអង្គចូលជាថវិកា ឬធ្វើបុណ្យឧទ្ទិសបញ្ជូនកុសល មិន ដែលខានឡើយ លើកលែងតែព្រះអង្គមិនបានជ្រាបជាដំណឹង។*

*ជាបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំបាទ សូមគោរពអរព្រះគុណ អរគុណ ដ៏ជ្រាលជ្រៅអស់ពីដួងចិត្ត និង សូមឧទ្ទិសកុសល ពរសព្វសាធុការ សូមព្រះអង្គ អស់លោកអ្នកសប្បុរសព្រមទាំងគ្រួសារប្រកបតែនឹងសេចក្តី សុខ មានសុភមង្គលគ្រប់ប្រការ រីកចម្រើនលូតលាស់កុំបីឃ្លៀងឃ្លាតឡើយ ។*

**សូមអនុមោទនា**...

*ឃិន សុផល*

*អគ្គលេខាធិការសមាគម*

**សុន្ទរកថា លោក ឃិន សុផល**

**អគ្គលេខាធិការសមាគម**

**ក្នុង ឱកាសបុណ្យ ចូលឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣**

*ថ្ងៃអាទិត្យ ទី១៤ ខែមេសា ឆ្នាំ២០១៩*

*សូមនមស្ការព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ*

*សូមគោរពបងប្អូនរួមជាតិ ពុទ្ធបរិស័ទ*

*សូមគោរពលោកស្រី នាងកញ្ញា អស់លោក ទាំងអស់ ជាទីរាប់អាន។*

*ជាបឋម ក្នុងនាមគណកម្មការបុណ្យនៃសមាគមឧបត្ថម្ភពុទ្ធសាសនាខ្មែរ និងក្នុងនាម ខ្ញុំព្រះករុណា ខ្ញុំបាទផ្ទាល់ មានសេចក្តីរីករាយជាច្រើន សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ជូនចំពោះ ពុទ្ធបរិស័ទ បងប្អូនរួមជាតិ ញាតិមិត្តទាំងឡាយ ដែលមានសមានចិត្ត អញ្ជើញ ចូលរួមកុះករ ក្នុងពិធីបុណ្យចូលឆ្នាំកុរឯកស័ក ព.ស. ២៥៦៣ វេលាម៉ោង ១៥ និង ១២ នាទី នៅពេលរសៀល បន្តិចទៀតនេះ។*

*វត្តមាននៃអស់លោកអ្នក ជាសក្ខីភាព បង្ហាញឲ្យឃើញជាក់ស្តែង នូវសន្តានចិត្តរស់ រវើកនៃ ជនរួមជាតិខ្មែរ ក្នុងការរក្សាការពារប្រពៃណី វប្បធម៌ ជំនឿសាសនា ដែលជាព្រលឹង ជាមរតក ដ៏ ថ្លៃថ្លារបស់ខ្មែរយើង ទោះបីកាលៈទេសៈបានតម្រូវឲ្យយើងមករស់នៅឆ្ងាយពី មាតុភូមិជាទី ស្នេហា ក៏ដោយ។*

*សូមរំលឹកថា ដោយសារទឹកចិត្តសប្បុរសធំទូលំទូលាយនៃសមាជិក សមាជិកាទាំង អស់របស់ សមាគម បងប្អូនរួមជាតិ ពុទ្ធបរិស័ទ និងញាតិមិត្រទាំងឡាយ សមាគម និងព្រះ សង្ឃ ខិតខំប្រឹង ប្រែង ធ្វើឲ្យបានសម្រេចនូវគោលដៅសំខាន់ៗ ដែលជាការចាំបាច់របស់បង ប្អូនរួមជាតិ និង ពុទ្ធបរិស័ទ ។*

*យើងមានជំនឿដ៏មុតមាំថា ដរាបណាជនរួមជាតិខ្មែរនៅតែមានសាមគ្គីភាព ជុំវិញ គោលការណ៍ទាំងឡាយ ដែលជាមូលដ្ឋាននៃជាតិរបស់ខ្លួន ប្រទេសជាតិខ្មែរ វប្បធម៌ អរិយធម៌ ព្រះពុទ្ធសាសនា ព្រលឹងខ្មែរ នឹង មិនរលាយសាបសូន្យឡើយ។ គឺសាមគ្គីភាព រវាងខ្មែរនិងខ្មែរ គ្រប់ជាន់ថ្នាក់ គ្រប់ទិសទីនេះហើយ ដែលនឹងនាំឲ្យជាតិខ្មែរបានជ័យជំនះ លើមារសត្រូវ ទាំងអស់ ជាមិនខានឡើយ។ យើងគប្បីពង្រឹងសាមគ្គីភាពនេះឲ្យកាន់តែរឹងមាំ ថែមទៀត ដើម្បីឲ្យប្រទេសខ្មែរ ឆ្ពោះទៅកាន់ឋានៈជាប្រទេសឯករាជ្យថ្កុំថ្កើង រុងរឿង។*

*សូមពុទ្ធបរិស័ទជ្រាបថា សមាគម និងវត្តពោធិវង្ស ព្រមទាំងព្រះសង្ឃ ដែលលោក ប្រតិបត្តិដ៏ខ្ជាប់ខ្ជួននូវ ធម៌វិន័យ ហើយជាគ្រូ ជាមគ្គុទ្ទេសក៍នៃយើងគ្រប់ៗគ្នា គ្មានប្រកាន់ គណៈធម្មយុត្តិ ឬ មហានិកាយ គ្មាននៅក្រោមគណៈបក្សនយោបាយមួយណាឡើយ ឬក៏ជា កម្មសិទ្ធិរបស់ឯកជនណាមួយក៏គ្មានដែរ ដូចបានចែងច្បាស់ក្នុងលក្ខន្តិកៈនៃសមាគមស្រាប់។ ផ្ទុយទៅ វិញ វត្តពោធិវង្ស ជាទីកន្លែងមួយដែលពុទ្ធបរិស័ទ គ្រប់ជាន់ថ្នាក់ គ្រប់ទិសទី គ្រប់ ឋានៈ មានសេរីភាព មករួបរួមធ្វើបុណ្យក្នុងភាពសុខសាន្ត ក្សេមក្សាន្ត ស្រុះស្រួលរវាងគ្នាបិត ថេរថេរកាល។*

*ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ សូមអានុភាពនៃព្រះរតនត្រ័យជួយឲ្យជនរួមជាតិទាំង អស់ចូល រួមក្នុង មហាសាមគ្គីជាតិ ដើម្បីរកសុខសន្តិភាព កសាងមាតុភូមិខ្មែរ និងព្រះពុទ្ធ សាសនាឲ្យ បានចម្រុងចម្រើន ជាកិយ្យោភាពតទៅទៀត។*

*ជាទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមប្រសិទ្ធិពរ ឆ្នាំកុរឯកស័ក ជូនបងប្អូនរួមជាតិ ពុទ្ធ*

*បរិស័ទ ទាំងនៅក្នុងប្រទេស ទាំងនៅក្នុងសកលលោក ព្រមទាំងក្រុមគ្រួសារសូមបានប្រកប តែនឹង សេចក្តីសុខ ចម្រើន មានជោគជយ័សិរីសួស្តី សមតាមប្រាថ្នា កុំបីអាក់ខានឡើយ ។*

*សូមអរព្រះគុណ សូមអរគុណ*

Discours de Monsieur KHIN Sophâl
à l'occasion du premier jour du Nouvel Khmer
Année de Cochon - 14 Avril 2019

Mes respects à Madame Maud TALLET, Maire de Champs-sur-Marne, aux personnels de la Mairie de Champs-sur-Marne et aux invités présents.

Ce premier jour du nouvel an cambodgien, les bonzes et la communauté khmère en France sont très honorés par vos présences.

L'Association pour le Soutien du Bouddhisme Khmer et la Pagode Bodhivansa sont nées sur le sol de Champs sur Marne en 1983. Aujourd'hui, 36 ans après, elles ne cessent de progresser tant sur le plan moral qu'au soutien financier pour répondre aux besoins des Cambodgiens à l'intérieur et à l'extérieur du pays.

L'Association pour le Soutien du Bouddhisme Khmer est digne de conserver l'héritage des ancêtres malgré l'éloignement du pays natal.

A la pagode Bodhivansa, lieu d'accueil pour tout le monde, sont célébrées les fêtes religieuses et traditionnelles ainsi que les fêtes privées.

Nous exprimons du plus profond de notre cœur, l'expression des remerciements à Mme Maud TALLET, Maire de Champs-sur-Marne, de nous avoir soutenus et encouragés

Grâce à votre appui éminent, les jeunes Cambodgiens nés en France connaissent, leur langue, leur histoire, leur art, leur origine et leur terre embellie par la richesse naturelle qui fait ressurgir la valeur de la civilisation khmère.

Madame le Maire, Mesdames, Mesdemoiselles et Messieurs, de la Mairie de Champs sur Marne, nous vous adressons nos vœux les plus fervents pour la nouvelle année parfumés par nos sentiments de reconnaissance, Bonne année et Bonne santé.

Merci de votre attention

KHIN Sophâl
Secrétaire général de l'ASBK




Madame Maud TALLET, Maire de Champs-sur-Marne







Salut des drapeaux



Rab Bath រាប់បាត្រ



Chorale de l’hymne national khmer











Galerie des bords de Marne

Nous vous invitons à la **Galerie des bords de Marne** pour venir partager
une conférence consacrée au Cambodge le **dimanche 23 juin 2019 à 16h. Entrée libre.**
**Thierry Fournet** présentera son film : **« Il est minuit docteur Richner »** ,
**Daravichet Chai** dédicacera son livre : **« Soma, l'enfant de l'Angkar »**, et **Marion Hedin**
nous jouera au violoncelle des suites de **Bach** qu'affectionnait **Béat Richner.**
***Cette conférence sera suivie d'un buffet convivial pour lequel chacun de vous est mis à contribution.***

## Il est minuit docteur Richner Film de **Thierry Fournet** présenté par le réalisateur







*Le film retrace l'histoire de* ***Beat Richner****, pédiatre, médecin réputé en Suisse qui en 1991, décide de tout quitter pour travailler dans un hôpital au Cambodge. Mais* ***Beat Richner*** *n'est pas seulement médecin, il est aussi un violoncelliste confirmé et talentueux. Il soigne les enfants malades avec des médicaments tout autant qu'avec sa musique, vivant au milieu d'eux. À travers ce portrait singulier, c'est l'analyse du contexte médical aujourd'hui au Cambodge, et un regard sur une façon originale de prodiguer des soins. C'est aussi l'histoire de son aventure personnelle, dans un pays aussi magnifique que tourmenté, transformant la vie d'un homme ordinaire en personnage de légende universelle.*






Marion **Hedin**



## Soma, l'enfant de l'Angkar de **Ung Daravichet Chai**

Un certain nombre de témoignages ont été écrits par des survivants du génocide perpétré par Pol Pot. Celui-ci est particulier. A l'époque des faits, l'auteur, **Ung Daravichet Chai** est une jeune maman réfugiée en France avec son mari et leurs deux fils. Enceinte d'un troisième enfant en 1973, elle rentre accoucher au Cambodge et met au monde une petite fille. Un mois plus tard, la confiant à ses tantes, elle revient à Paris. Une séparation déchirante qui aurait dû être de courte durée. Quand la famille est en mesure de regagner le Cambodge, les Khmers rouges viennent d'envahir Phnom Penh. Plus aucune nouvelle ne filtre du pays, sinon les rumeurs d'événements sanglants. Débute alors une attente interminable. Dans ce livre, **Ung Daravichet Chai** raconte l'épopée dramatique de sa fille qui traversera l'enfer et la barbarie. A travers cette épopée, c'est de son pays que l'auteur veut aussi parler.
Une civilisation brillante anéantie en une journée.

Galerie des bords de Marne 91, promenade Hermann Régnier 93460 Gournay-sur-Marne 06.80.20.47.41



A la Galerie des Bords de Marne, le 23 juin 2019, Une brève présentation du bulletin de l'ASBK par le responsable du bulletin, Mr TEP Bounthakna (également Président de l'Association Centre des Documentalistes Cambodgiens), et les remerciements aux invités par le Vénérable Lam Seak et Mme Ung Daravichet CHAI.

Ravie KHIN

## Initiation à la méditation



A la veille du Nouvel An Khmer, le samedi 13 avril 2019, la famille de M. Alain RUBY

est venue à la Pagode Bodhivansa pour initier la « méditation », exposée par le Vénérable Lam Seak.

ក៉ាវី ឃិន Ravie KHIN

# ចុងភៅខ្មែរគ្រងពានមាស បង្កើនកិត្តិនាមមុខម្ហូបខ្មែរ កាន់តែល្បីលើឆាកអន្តរជាតិ




ក្បួនរថយន្ត និងម៉ូតូដង្ហែក្រុមចុងភៅជាប់ជ័យលាភីពីការប្រកួតចម្អិនម្ហូបលំដាប់អន្តរជាតិនៅប្រទេសថៃ។ រូបថត សហការី

***សៀមរាប***: ម៉ូតូប៉ូលិសបរនាំមុខបើកផ្លូវ បន្តដោយរថយន្តក្រុមវង់ភ្លេងឆៃយ៉ាំ ប្រគំចង្វាក់ប្រពៃណីពីរោះរន្ទាន់។ ក្បួនរថយន្ត និងម៉ូតូជាច្រើនគ្រឿងដែលអ្នកខ្លះលើកទង់ជាតិ ខ្លះលើកបដាជ័យលាភី និងបង្ហូតមេដាយយ៉ាងមានមោទនភាពក្រោមសំឡេងឧគ្ឃោសនស័ព្ទបន្ទរកងរំពងជាសញ្ញាអបអរសាទរក្រុមចុងភៅកម្ពុជាបានឈ្នះពានមាស និងមេដាយជាច្រើនគ្រឿងជូនជាតិមាតុភូមិ។

ក្រុមចុងភៅកម្ពុជា ២៦ នាក់ និងអ្នកហែហម ៦ នាក់ដែលដឹកនាំដោយប្រធានសមាគមចុងភៅកម្ពុជាបានឈ្នះពានរង្វាន់មាស ១ មេដាយមាស ៣ គ្រឿង ចំពោះការប្រកួតចម្អិនម្ហូបប្រភេទ the Best Asian Gourmet Challenge រួមជាមួយមេដាយប្រាក់ ៦ និងសំរឹទ្ធ ១៧ គ្រឿងក្នុងប្រភេទផ្សេងៗនៃព្រឹត្តិការណ៍ Thailand Ultimate Chef Challenge 2019 ដែលរៀបចំឡើងពីថ្ងៃទី ២៧ ខែឧសភាដល់ថ្ងៃទី ១ ខែមិថុនាក្នុងប្រទេសថៃ។

លោក ឡុង ប៊ុនហោ ប្រធានសមាគមចុងភៅកម្ពុជា (CCA) បានឲ្យដឹងថា៖ «ប្រាកដណាស់ក្រុមចុងភៅចង់បានសញ្ញាបត្រ កិត្តិនាម ចំណេះដឹងទូលំទូលាយ និងយល់ដឹងពីម្ហូបជាតិសាសន៍ដទៃក្នុងការប្រកួតអន្តរជាតិនេះ។ ប៉ុន្តែពួកគាត់ក៏ចង់នាំយកម្ហូបខ្មែរទៅបង្ហាញនៅក្រៅប្រទេសដើម្បីលើកមុខមាត់ប្រទេសជាតិផងដែរ»។

លោក ប៊ុនហោ ដែលជាម្ចាស់ភោជនីយដ្ឋានម្ហូបខ្មែរ អង្គារដី ផងនោះបានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ថា៖ «ពានរង្វាន់នេះពិតជាមានសារៈសំខាន់ណាស់ក្នុងវិស័យម្ហូបអាហាររបស់ប្រទេសកម្ពុជាក៏ដូចជាបុគ្គលដែលមានអាជីពជាចុងភៅ។ វិស័យម្ហូបអាហារខ្មែររឹតតែមានការទទួលស្គាល់ពីឆាកអន្តរជាតិដោយសារយើងជ្រើសរើសយកមុខម្ហូបខ្មែរចូលរួមប្រកួតរៀងរាល់ឆ្នាំ»។

ជាប្រធានក្រុមក្នុងចំណោមបេក្ខភាព ៣ រូបដែលដណ្ដើមពានមាស ១ និងមេដាយមាស 3 លោក ឈន ប៊ុនឈួ បម្រើការនៅក្រុមហ៊ុនហ្គោលឌិន ផេមភលគ្រុប តែងតែមានការចូលរួមប្រកួតលើឆាកអន្តរជាតិនានាដើម្បីលើកមុខមាត់ប្រទេសជាតិ។




ចុងភៅកម្ពុជា ២៦ នាក់ឈ្នះពានរង្វាន់មាស ១ មេដាយមាស ៣ ។ រូបថត សហការី

ចុងភៅដែលមានបទពិសោធការងារ ១១ ឆ្នាំរូបនេះបានឲ្យដឹងថា៖ «ជាមួយចិត្តស្រឡាញ់ និងចង់លើកស្ទួយម្ហូបអាហារខ្មែរ ខ្ញុំក៏ដូចជាក្រុមរបស់ខ្ញុំផ្ទាល់មានការប្ដេជ្ញាខ្ពស់ ដោយសម្រេចចិត្តថា ទោះបីជាជាប់ ឬធ្លាក់ក៏ត្រូវតែយកម្ហូបខ្មែរទៅកាន់ឆាកអន្តរជាតិ ដើម្បីឲ្យគេបានស្គាល់ និងភ្លក្សរសជាតិផងដែរ»។

លោក ប៊ុនឈូ ដែលបានចូលរួមប្រកួតក្នុងព្រឹត្តិការណ៍មុខម្ហូបនៅប្រទេសថៃចំនួន ៤ លើកមកហើយ បានបន្តថា៖ «គោលបំណងរបស់ខ្ញុំក្នុងការចូលរួមប្រកួតនោះគឺចង់ឲ្យអន្តរជាតិទទួលស្គាល់ថា កម្ពុជាមានសមត្ថភាពក្នុងការអភិរក្ស អភិវឌ្ឍវិស័យម្ហូបអាហារឲ្យមានការរីកចម្រើនដូចប្រទេសនានាក្នុងតំបន់អាស៊ី និងសកលលោក»។

ស្ថិតក្រោមការវាយតម្លៃពីសំណាក់គណៈកម្មការមកពីថៃ តៃវ៉ាន់ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងបណ្ដាប្រទេសដទៃទៀតពួកគេបានផ្ដល់ពិន្ទុទៅលើសោភណភាព រសជាតិ អនាម័យ និងពេលវេលា ជាពិសេសសាមគ្គីភាពក្នុងក្រុមទៅលើបេក្ខជនប្រកួតមកពី ១៤ ប្រទេសដែលមានអ្នកចូលរួមប្រមាណ ១៤០០ នាក់។

លោក ឡុង ប៊ុនហោ ដែលតែងតែផ្ដល់មតិយោបល់ គំនិត និងបច្ចេកទេស បានលើកឡើងថា៖ «ចុងភៅដែលចូលរួមប្រកួត សុទ្ធតែជាបុគ្គលិកតាមសណ្ឋាគារ និងភោជនីយដ្ឋាន ហើយអ្នកខ្លះមានហាងផ្ទាល់ខ្លួនទៀត។ គណៈកម្មការវាយតម្លៃមើលលើការងារជាក្រុមថា តើពួកគេមានសាមគ្គីភាព ឬក៏អត់ ហើយពេលប្រកួតកន្លែងប្រកួតមានអនាម័យ និងសណ្ដាប់ធ្នាប់ល្អ ឬក៏អត់?។ រសជាតិបានដល់កម្រិតដែលគណៈកម្មការអាចឲ្យពិន្ទុបានកម្រិតណា?»។



ក្រៅពីការចម្អិន ក្រុមចុងភៅត្រូវរៀបរងដឹកសម្ភាររាប់រយគីឡូក្រាម។ រូបថត សហការី

ចុងភៅមានបទពិសោធការងារជាង ១ ទសវត្សរ៍រូបនេះបាននិយាយថា៖ «ទោះបីជាពេលខ្លះ យើងមានការប៉ះទង្គិចនូវពាក្យសម្ដីគ្នាខ្លះយ៉ាងណាក៏ដោយ ក៏ពួកយើងបានសម្របសម្រួលគ្នាដើម្បីរួមសម្រេចគោលដៅ និងក្ដីស្រមៃតែមួយ»។

ពីក្រោយសម្រស់ និងក្លិនឈ្ងុយប្រហើរនៃមុខម្ហូបលើចាន ជាទូទៅពេលចេញដំណើរទៅក្រៅ កីឡាករបាល់ទាត់មិនចាំបាច់វេចខ្ចប់បាល់ឡើងយន្តហោះឡើយ។ កីឡាករប្រដាល់យ៉ាងច្រើនណាស់ ស្ពាយតែសម្ភារមួយបង្វេចជាការស្រេច។

ប៉ុន្តែភាពងាយស្រួលទាំងអស់នេះមិនមែនសម្រាប់ក្រុមចុងភៅ ពេលចេញទៅប្រកួតក្នុងព្រឹត្តិការណ៍ Thailand Ultimate Chef Challenge 2019 នោះឡើយ។

លោក ឡុង ប៊ុនហោ បានប្រាប់ថា៖ «ក្រុមចុងភៅយើងត្រូវដឹកជញ្ជូនសម្ភារប្រកួតច្រើនណាស់ រាប់ចាប់ពីខ្លះគ្រប់ប្រភេទ កាំបិត ចានឆ្នាំង និងសម្ភារផ្ទះបាយចាំបាច់ដែលមានទម្ងន់រាប់រយគីឡូក្រាមឯណោះ។ នៅកន្លែងប្រកួត គេផ្ដល់ឲ្យតែបរិក្ខារធំៗមួយចំនួនដូចជា ទូក្លាសេរសាច់ ម៉ាស៊ីនម៉ៃក្រូវេវ និងចង្ក្រានជាដើម»។

លោក ឈន ប៊ុនឈួ ប្រធានក្រុមក្នុងពេលប្រកួតបានបន្ថែមថា៖ «ពិតណាស់ យើងត្រូវការចំណាយថវិកាច្រើន ហើយអ្វីដែលកាន់តែលំបាកថែមទៀតនោះ គឺការធ្វើដំណើរ ស្នាក់នៅ និងហូបចុក ហើយពេលខ្លះមានការហាមឃាត់ពីសំណាក់តម្រួតថៃនៅឯព្រំដែនទៀតផង»។

ស្ថិតក្នុងចំណោមមុខម្ហូបប្រកួតទាំង ១០ រួមទាំងបង្អែម ១ មុខដែលកម្ពុជាទទួលបានជ័យជម្នះនោះដូចជា ញាំក្រូចថ្លុងបង្គាទន្លេ សាច់គោអាំងទឹកប្រហុក សម្លប្រហើរត្រីឆ្អើរ អាម៉ុកត្រី ការីសាច់មាន់ ផាកង្កែបម្រេចខ្ចី ខប៉េងប៉ោះ ត្រីបំពងជ្រក់ស្វាយ បាយចំហុយជាមួយសណ្ដែកខ្មៅ (ស្រដៀងក្រឡាន) និងបង្អែមសង់ខ្យាល្ពៅ ដោយទទួលបាន ៩៥ ពិន្ទុនោះការស្វែងរកបន្លែ ត្រី សាច់សម្រាប់រៀបចំជាម្ហូបទាំង ១០ មុខពិតជាសំខាន់បំផុត។

លោក ប៊ុនហោ បានប្រាប់ថា៖ «ដាក់ស្ដែងមុខម្ហូបកង្កែបឆាម្រេចខ្ចី ក្រុមចុងភៅវេចខ្ចប់ម្រេចខ្ចីពីខ្មែរ រួចទៅរកដើរទិញកង្កែបនៅផ្សារថៃ។ ពេលពួកគាត់ទៅដល់ភ្លាម ពួកគាត់ចាប់ផ្ដើមដើរផ្សារ និងគិតថា តើប៉ុន្មានផ្សារទើបគាត់អាចរកបានអីវ៉ាន់ ១០ មុខហ្នឹង។ អត់មាន ១ ផ្សារអាចរកបាន ១០ មុខទេ។ កម្មវិធីប្រកួតនេះគេឲ្យពេលវេលា ៣ ម៉ោងបើធ្វើមិនទាន់ យើងនឹងត្រូវធ្លាក់ពីការប្រកួត។ ១ មុខម្ហូបមាន ៦ ចានគឺត្រូវតែដូចគ្នា ប៉ុនគ្នា និងរសជាតិតែមួយ»។

ប្រធានសមាគមចុងភៅកម្ពុជាដែលជួយដល់សមាជិកចុះឈ្មោះចូលរួមប្រកួត ព្រមទាំងរៀបចំកិច្ចប្រជុំ និងជួបជុំធ្វើម្ហូបសាកល្បងមុនពេលចេញដំណើរបានជួយថវិកាបន្តិចបន្តួច និងស្វែងរកអ្នកឧបត្ថម្ភ ដោយថវិកានៅសេសសល់តិចតួចជាការរ៉ាប់រងរបស់ក្រុមចុងភៅ។

លោក ឡុង ប៊ុនហោ បានប្រាប់ថាក្រៅពីប្រទេសថៃ ក្រុមចុងភៅកម្ពុជាបានទៅប្រទេសចិន វៀតណាម ឥណ្ឌា និងសិង្ហបុរី ព្រមទាំងបានធ្វើបទបង្ហាញពីមុខម្ហូបខ្មែរនៅតាមបណ្តាប្រទេសមួយចំនួនទៀត ដូចជា កូរ៉េខាងត្បូង ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា និងថៃជាដើម។

ជាមួយសមាជិកចុងភៅ ២៦៥ នាក់សមាគមចុងភៅកម្ពុជាមានបេសកកម្មកៀរគរចុងភៅជំនាញក្នុងបំណងជួយផ្សព្វផ្សាយមុខម្ហូបខ្មែរទាំងលើឆាកជាតិ និងអន្តរជាតិព្រមទាំងជួយគាំទ្រដល់ចុងភៅជំនាន់ថ្មីតាមរយៈការបើកវគ្គបណ្តុះបណ្តាល និងផ្តល់ឱកាសចូលរួមប្រកួតគ្រប់កម្រិតថ្នាក់៕

## Gastronomie : Le Cambodge se distingue dans une compétition de cuisine asiatique à Bangkok

La cuisine cambodgienne s'est distinguée lors de la compétition gastronomique "Thailand Ultimate Chief Challenge 2019 – Best Asian Gourmet Challenge", organisée à Bangkok.



Le Cambodge gagne la première place dans une compétition de cuisine asiatique à Bangkok

Long Bunhor, président de l’Association des cordons bleus cambodgiens dirigeait l’équipe cambodgienne pour cette compétition qui s’est déroulée du 26 mai au 1er juin. Les plats cambodgiens, a déclaré Long Bunhor, ont obtenu un trophée d’or et 27 médailles d’or, d’argent et de bronze.

Le chef du service touristique de la province de Siem Reap, Ngov Sengkak, a déclaré qu’il considère ce succès comme une fierté mais aussi comme une excellente promotion touristique. Selon lui, le ministère du Tourisme souhaite privilégier l’utilisation d’aliments de qualité, bien servis et préparés de façon hygiénique.



Des chefs du Cambodge, de Chine, Hong Kong, Macao et Taïwan, de Corée du Sud, du Vietnam, de Malaisie, des Philippines, d’Indonésie, de Singapour et du Pakistan, ainsi que les trente meilleurs cordons bleus thaïlandais, ont participé à cette compétition.







Fondée en 2013, l'Association des cordons bleus cambodgiens a été créée en 2013 au Cambodge pour permettre aux chefs cambodgiens de participer aux divers concours culinaires régionaux et internationaux. Depuis sa création, les chefs de l'association ont gagné de nombreuses médailles lors des compétitions régionales.

**TEP KOLAVUDH ទេព កុលវុឌ**

# *Jessa KHAN sur le toit du monde de JIU -JITSU*




L'americano-khmère Jessa Khan a remporté le week-end dernier quatre médailles d'or au SJJIF World, un prestigieux tournoi international de jiu jitsu. Ces titres viennent garnir une année somptueuse, durant laquelle Jessa a également glané trois titres de championne du monde et la médaille d'or aux Jeux Asiatiques en Indonésie. Une ambition de championne. Quelques heures seulement après avoir concrétisé ce quadruplé au SJJIF World de Long Beach en Californie, Jessa Khan pense déjà à la suite. En ligne de mire, les tournois EBI et No Gear Worlds au mois de décembre prochain. « *Je reste toujours concentrée sur ce que j'ai à gagner*, explique la jiujitsuka. ***J'ai encore beaucoup de rêves et beaucoup de titres à aller chercher***. » À 17 ans, Jessa Khan a pourtant sans conteste dominé de la tête et des épaules la scène du jujitsu international féminin cette année. À son niveau en tout cas. La ceinture bleue, portée très souvent entre 16 et 18 ans. Son objectif est de passer ceinture noire

l'année prochaine, l'âge minimum étant établi à 18 ans, pour lui ouvrir les portes des titres les plus glorieux.




Jessa atteint la plus haute marche du podium aux championnats du monde en juin dernier. ©Instagram **jessa.khan**

**Une motivation infaillible**

L'entraînement professionnel prend du temps, surtout à 17 ans. La vie quotidienne de Jessa tourne en permanence autour du jujitsu. C'est un passage obligatoire pour espérer tout remporter. « *Je m'entraîne en Californie tous les jours, **20 à 25 heures par semaine**. J'enseigne également cet art martial aux plus jeunes. Le jiujitsu prend une part très importante dans ma vie. C'est très difficile de se concentrer sur le reste, mais je m'accroche* », assure-t-elle. Jessa suit des cours par correspondance pour rester au fait, elle est sûr d'elle, « *je ferais du jujitsu mon métier*. »En 2010, à ses débuts, Jessa considère cet art martial comme un loisir. À 9 ans elle ne pense pas vraiment à la suite. Trois ans plus tard, après avoir participé à quelques compétitions junior, le jujitsu prend de l'ampleur dans sa vie et elle se focalise de plus en plus sur ce sport, **pour ne plus le lâcher par la suite**. C'est son père, Peter Khan, né au Cambodge et parti vivre aux États-Unis, qui l'a introduite à ce sport de combat. Jessa

possède la double nationalité, khmère et américaine. Ce qui lui a ouvert les portes des Jeux Asiatiques au mois d'août dernier.

Jessa est déjà entrée, à seulement 17 ans, dans l'Histoire du Cambodge et de l'Asie.
Sa motivation, ses ambitions et son travail l'amèneront peut-être au sommet de son art, elle fait tout pour.



Jessa accompagnée de son père,

Peter Khan, sur sagauche. ©Instagram jessa.khan

## Entrée dans l'Histoire

Le jiujitsu a été instauré cette année au programme des Jeux Asiatiques. Jessa a pu participer à cette 18e édition organisée en Indonésie. Mieux que cela, elle a même remporté la compétition et devient **la première médaillée d'or de l'Histoire** du jiujitsu aux Jeux Asiatiques, dans la catégorie des moins de 49kg. « *C'est une immense fierté d'avoir pu revêtir le maillot khmer et représenter mes origines. Je suis très reconnaissante envers le Cambodge de m'avoir permis de participer à ces Jeux Asiatiques. Je suis venu au royaume après la compétition pour voir ma famille et rencontrer les supporters, quel souvenir incroyable* ! », s'extasie la championne.




Une joie communicative pour
la jeune khmère après sa victoire aux Jeux
Asiatiques.©Instagram jessa.khan

Thibault Bourru, le 01 nov. 2018

**TEP KOLAVUDH ទេព កុលាវុធ**

# DEUXIEME JOURNEE CULTURELLE KHMER
# 6 JUILLET 2019 - BUSSY-SAINT-GEORGES

Le 6 juillet 2019 s'est tenue la 2ème édition de la Journée culturelle khmer[1] et Sportive organisée par la communauté des associations khmer en France à Bussy-Saint-Georges. Elle avait pour objectif de faire revivre en une journée l'esprit khmer dans des domaines aussi divers que la culture, la littérature, l'art, les coutumes, les jeux et les danses populaires sans oublier la mémoire de nos héros sous son aspect religieux et historique.

La réalisation de cette journée s'est effectuée avec l'aide de Monsieur le Maire de Bussy-Saint-Georges et son équipe municipale qui nous ont gracieusement mis à disposition le Gymnase Maurice HERZOG, et à qui nous présentons notre gratitude et nos remerciements.

Nous saluons également l'équipe de volontaires cambodgiens qui a contribué à la décoration et à la mise en place des dispositifs de scène, des tables, des chaises, des stands pour accueillir les participants, et le rangement une fois la fête terminée.

Cette Journée Culturelle a débuté par le passage symbolique de la « Porte Banteay Srey » des organisateurs, suivi de la cérémonie religieuse bouddhique pour la Mémoire de nos héros et compatriotes morts pour la nation khmer[1]. Ce symbole marque la volonté de promouvoir l'identité nationale khmer.

Les compétitions sportives (Football et Ping-pong) ont eu lieu à l'extérieur de la salle, tandis que les jeux populaires khmer[1] se sont déroulés à l'intérieur.





Afin de promouvoir la chorégraphie de la danse populaire khmer[1], une démonstration des pas de danse a été mise à l'honneur par une professeure de danse avec la participation nombreuse du public. Présentant aux invités français et cambodgiens les différents aspects de la culture khmer[1], les arts martiaux, le Chhayam, les Sept couleurs de l'habit traditionnel, la circumambulation des babils dans le mariage khmer[1] et les danses folkloriques ont été fort appréciés.




















Cette deuxième édition de la Journée Culturelle khmer(1) étant placée sous le symbole de Samdech CHUON Nath, Chef des bonzes khmer(1) et Père de la littérature et linguistique khmer(1), les jeunes diplômés se voient récompensés par la remise de statuette Proum Bayon. La gratitude et la grâce aux parents et aux ancêtres ont également été rappelées. Elles font partie de nos traditions.
Quatorze associations de la région parisienne et de l'Oise ont participé à cette 2ème édition de la Journée culturelle khmer(1) :

Association Famille Dharma Métta

L'association des Bouddhistes Khmer Kampuchéa Krom dont le siège se trouve à la pagode Chantarainsey, présente son programme d'agrandissement des bâtiments dans l'enceinte de cette pagode.

Association des Khmer Kampuchéa Krom en France (AKKKF)

Association d'Aides aux Handicapés du Cambodge. Créée en 1991, elle œuvre au Cambodge depuis 1992 grâce à la création d'un centre de soins et de consultations ambulatoires à Phnom-Penh (1992–2003). Elle parraine des enfants handicapés, assurant leur scolarisation jusqu'à l'obtention d'un métier, et fournit des puits aux familles ayant un handicapé ainsi qu'aux familles démunies. A ce jour, 106 puits ont été construits. Son stand présente également le dictionnaire des termes médicaux Français-khmer-Anglais avec les explications en khmer et 1360 images. Il est destiné à la population khmer, aux professionnels de santé et aux étudiants en médecine.

PRODAL BORAN (Boxe khmer) a été créée en 2007, afin de promouvoir, à travers la Boxe Khmère, le patrimoine Cambodgien et les valeurs de respect et d'humilité. Cette association a présenté ses pratiquants dans différentes manifestations en France.

Association des Anciens Etudiants Khmer de l'Université des Beaux Arts du Cambodge en France (AEKUBACF).

L'Ecole khmer de Noisiel a été créée avec l'arrivée des premiers réfugiés cambodgiens. Le but de l'association est d'enseigner la langue et la culture khmère aux enfants comme aux adultes, d'origine cambodgienne ou non, habitant à Marne-la-Vallée.

Association Fraternité Franco-khmer de l'Essonne (AFFKE) a pour objectifs de promouvoir et favoriser la pratique des activités culturelles et traditionnelles khmères. Elle pratique également la solidarité sous toutes ses formes en développant notamment des activités de formation et d'animation en direction des jeunes et de la famille.

Le massage khmer est un massage ancien et traditionnel qui trouve son origine à l'époque du royaume khmer, actuellement le Cambodge. C'est une technique de massage à but thérapeutique. Un livre est en cours de rédaction pour servir de support à un enseignement.

Fédération européenne de Bokator a été créée en 2014 par la famille Sebire en 2014. Première initiatrice du Bokator en Europe, elle garantit techniquement la formation des instructeurs et des élèves à travers les livrets d'apprentissage, les vidéos de formation et les passages de grade. Elle a par la suite créé des antennes dans d'autres pays d'Europe.

Centre Krom Nguy a pour objectif de contribuer au développement des ressources humaines au Cambodge par le transfert de technologie, la formation et l'insertion professionnelle.

Association pour le Centre de Formation de la Diaspora khmer (CEFODIA).

Association des artistes Associés khmer dont les objectifs sont de donner des cours de danses classiques et folkloriques khmer et de présenter les spectacles.

Samaki Kohn Khmer.

Le Maire de Bussy-Saint-Georges nous a fait l'honneur de sa présence lors de cette Journée Culturelle khmer[1]. Nous lui présentons nos remerciements. L'évènement s'est achevé par une soirée dansante animée par l'orchestre ORIGINZ et les rappeurs Mékong Soul.
Les organisateurs ont décidé de renouveler la Journée Culturelle khmer le dimanche 5 Juillet 2020 à Bussy Saint Georges et de participer activement à la fête de Nouvel An en avril 2020 dans une des pagodes de la Région Parisienne.

---

1. : Le mot khmer est un nom propre et reste invariable.

ដារ៉ាវី ប៉ុន Daravie PON

# អានិសង្ស[១] សង់សាលា

**ក**) ការកសាងសាលា,កុដិ ,វិហារ ជាអាមិសទាន ។ កាលបើសំណង់បានសាងសង់រួច ហើយ ,ពុទ្ធបរិស័ទនាំគ្នា ធ្វើបុណ្យឆ្លង បញ្ចប់គំរោងការសាងសង់ ,ទុកជាគរុភ័ណ្ឌ ,ជាសម្បត្តិសង្ឃ ។ សង្ឃបានស្នាក់នៅ ។ សាធារណជន ក៏បានប្រើប្រាស់ ។ សម្បត្តិនេះប្រើជាកន្លែងសិក្សា , ផ្សាយធម៌ ។ សាធារណជននាំគ្នាធ្វើបុណ្យ , ចំឡងសត្វ , តាមប្រពៃណីនិងតាម សាសនា ព្រះពុទ្ធ ។

អ្វីជាព្រះរតនៈត្រ័យ ?។ រតនៈ = វត្ថុដែលធ្វើចិត្តឱ្យរីករាយ មានមាសពេជ្រ ជាដើម ។ ត្រ័យ=បី ។ រតនត្រ័យ =របស់បីជាទីស្រឡាញ់ពេញចិត្ត ។ ព្រះរតនត្រ័យ = ព្រះពុទ្ធ,ព្រះធ៌មនិង ព្រះសង្ឃ ដែលជាទី ពឹងទីពំនាក់មនុស្សលោក ។

អ្នកកសាងគរុភ័ណ្ឌ មានឈ្មោះថា " អ្នកធ្វើបុណ្យ " ។ បុណ្យជានាមធម៌ នៅក្នុងរូប និងក្នុង ចិត្តអ្នក ធ្វើបុណ្យ ។ បុណ្យជា គុណធម៌[២] , ជាកុសល, ជាគ្រឿងជំរះសន្តានចិត្ត, ជាសេចក្តីសុខ , សុខទាំងកាយ ,សុខទាំងចិត្ត ដែលយើងម្នាក់ៗ ស្វែងរក ។ ក្នុងជំនឿបុណ្យបាប ,កម្មផល , បុគ្គល មានសទ្ធារៀបចំធ្វើបុណ្យ , កសាងសាលា, កុដិ ,វិហារ ។ល។ បានជាប្រយោជន៍ ដល់មនុស្សទូទៅ និងខ្លួនផ្ទាល់ ។ ប្រយោជន៍នេះ ជាទីពឹង , ជាកុសលរបស់បុគ្គល ក្នុងលោកនេះ និងលោកខាងមុខ ។

ភិក្ខុ ជាសមណៈ ,ជាអ្នកបួស , អ្នកខ្លាចភ័យ ក្នុងវដ្តសង្សារ ,អ្នកខ្លាចបាបជានិច្ច , អ្នកព្យាយាម ដុតកំដៅកិលេស , ដុតបំផ្លាញអំពើអាក្រក់ ,សន្សំអំពើល្អ , ជាគំរូដល់ឧបាសក ។ ព្រះសង្ឃជាសាវក នៃព្រះមានព្រះភាគ ។ ព្រះសង្ឃមានសីល ។លោកប្រតិបត្តិ ដ៏សមគួរតាមសីល ,សមាធិនិងបញ្ញា ។ លោកជាស្រែបុណ្យចាំទទួល ទានជាចតុបច្ច័យ របស់អ្នកធ្វើបុណ្យ , ផ្សាយបុណ្យនិងឧទ្ទិសកុសល ជូនទៅ ញាតិមិត្តគ្រូបាធ្យាយ ព្រមទាំងអ្នកមានឧបការគុណ ។

ភិក្ខុនិងឧបាសកប្រាស្រ័យទាក់ទងគ្នា , ជួយជ្រោមជ្រែងគ្នា តម្កើងព្រះពុទ្ធសាសនា មានការ សាងសង់ ,ការផ្សាយធ៌ម ,ជួយអប់រំគ្នាដើម្បីសេចក្តីចំរើន , ជាប្រយោជន៍ និងសេចក្តីសុខ ។

**១**) និទានរឿង នាងរោហិណី ។

នាក្រុងកបិលវត្ថុ , ព្រះញាតិវង្សបាននាំគ្នាមកថ្វាយបង្គំព្រះថេរៈ ដែលនិមន្តមក ប្រកប ដោយ បរិវា ៥០០អង្គ ។ ព្រះថេរៈក៏សួររកប្អូនស្រី នាងរោហិណី មិនមក ថ្វាយបង្គំ ។ ដោយបានជ្រាប ពី អាការៈ ថានាងមានការ ខ្មាស អៀននិងជម្ងឺស្រែង , ជម្ងឺស្បែកកើតពេញខ្លួន , ព្រះថេរៈ ក៏ឱ្យគេទៅហៅ នាងមកជួប ។ នាងរោហិណី ក៏មក ថ្វាយបង្គំ ហើយរាយរាប់ តាមដំណើរ អាការៈឈឺចាប់ ។ ព្រះថេរៈក៏សួរថា តើនាងមិន ចង់ ធ្វើបុណ្យទេឬ? តើព្រះអង្គចង់ឱ្យខ្ញុំម្ចាស់ ធ្វើអ្វី? ចូរនាងសាងសាលា

ទុកជាអាសនៈ ។ តើបានអ្វីសាងសង់សាលា ព្រះអង្គ ? ក្រែងនាងមានធនក័ណ្ឌខ្វះដែរឬ ? មានខ្វះដែរ ព្រះអង្គ ។ អើនាងលក់របស់ខ្វះទៅ ហើយយក ប្រាក់នោះមក សាងសង់ ។ អាត្មា នឹងអង្វរ ញាតិឱ្យជួយ , ឯអាត្មាក៏ជួយ ឧបត្ថម្ភនាងដែរ ។ សាលាពីរជាន់សង់ហើយ , ព្រះថេរៈក៏ប្រាប់ប្អូន ឱ្យថែទាំសាលា , បោសសម្អាត , ដងទឹកដាក់សាលាទុកប្រើប្រាស់ ជានិរន្តន៍ , កុំអាក់ខានឡើយ ។ ដោយអំណាចបុណ្យ ជម្ងឺស្បែក ក៏ធូរស្បើយ ។

ដំណើរក្រោយមកនាងពេហិណីក៏ ចាប់ជាតិជាទេវតា មានរូប ឆោមល្អអស្ចារ្យ ។ កាលនោះមានទេវបុត្រ៤អង្គ ចោមរោមចង់បាននាង ជាមហេសី ។ ៤ ទេវបុត្រទាំង អង្គ សំរេចចិត្តថា នាំគ្នាទៅប្តឹងព្រះឥន្ទ្រ ។ លុះទៅដល់ , ព្រះឥន្ទ្រក៏សំរួលថា ៖ ថ្វាយបង្គំ បវរទេពធីតា ទៅណាមកណា បានជាមាន ទេវតាកម្លោះទាំងឡាយ ស្រស់បំព្រង ហែហមច្រើនម្ល៉េះ ? តើមកជួប យើងមាន ហេតុអ្វី ? ។ ព្រះឥន្ទ្រ ក៏សួរនាំ ទេវតាទាំងអស់ថា តើអាច រាប់រៀប បុព្វហេតុ ស្នេហាបាន ឬទេ ? ក្រោយពីបានស្តាប់សេចក្តីរាយការណ៍នៃទេវតា មួយអង្គម្តងៗ ហើយ ព្រះឥន្ទ្រក៏ឆ្លើយដោយសង្ខេបថា ៖

-ទេវតាទី១ ចិត្តស្រឡាញ់អ្នក នៅមិនស្ងៀម ។ ចិត្តអ្នកចេះតែរំភើបញាប់ញ័រ, ជ្រួល ច្របល់ភ័យអរ ៗ ។ បេះដូងលោតព្រួ ក្តុងក្តាំងៗ ដូចគេទួងស្គរ កណ្តាលលានប្រយុទ្ធនៃសមរភូមិ ។

-ទេវតាទី២ ចិត្តស្រឡាញ់អ្នកហូរចេញ ពី បេះដូង ក្រៀមក្រំ ទៅទំគ្របលើស្រមោល រូបនាងមិនដាច់ពេលវេលា ដូចទឹកហូរពីភ្នំ ។

-ទេវតាទី៣ ចិត្តស្រឡាញ់អ្នក មានទំហំ ធំហួសនិស្ស័យ បាត់មុខនាង មិនបាន ។ ភ្នែកអ្នកទាំងគូសំឡឹងភក្ត្រនាង ស្ទើរតែលៀនប្រស្រី , និងលៀនដូចភ្នែកក្តាម ។

-ទេវតាទី៤ ចិត្តស្រឡាញ់អ្នក ជម្រុញចិត្ត មិន នៅស្ងៀម, មិនឱ្យហ្នឹងហ្ន៎ ដូចជម្ពូតា ។ អ្នកមានអាការៈឆ្វេឆ្វា ចុះឡើង មិនឈប់ស្រាក ប្រៀបបានចុងទង់ជ័យ បក់តាមដំនោខ្យល់ និងខ្យល់ព្យុះ បោកមិនឈប់ ។

ឯខ្ញុំជាព្រះឥន្ទ្រ អ្នកកាត់ក្តី យល់ថាចិត្តស្រឡាញ់ ទេវតា គ្រប់រូប ត្រឹមត្រូវ សមរម្យ ទាំងអស់គ្នា ។ ចិត្តអ្នកទាំង៤នៅខ្សោយ អ្នកមកតវ៉ាគ្នា ជាមួយខ្ញុំ មិនខ្លាំងណាស់ណាទេ ។ គ្មានសន្ទុះខ្លាំងក្លា ព្រោះអ្នកនៅទ្រាំបាន អ្នកនៅតស៊ូទ្រាំបាន ។

ចិត្តអ្នកជាកំសួល មនោសញ្ចេតនា ផ្តេកផ្តួលតាម កំសួលចិត្ត ។ ថ្ងៃក្រោយ ថ្ងៃមុខ អ្នកគ្មានបានប្តេជ្ញាឱ្យជ្រៅជ្រះ ថាសំរេចដូចម្តេច ? អ្នកបានត្រឹមតែ ឈ្លោះគ្នា តវ៉ា ចង់បាន បវរទេពធីតា ជាមហេសី តែប៉ុណ្ណោះ ។ សូមទេវតា ទាំង៤ ស្តាប់ខ្ញុំឱ្យច្បាស់ ថា តាំងពីខ្ញុំបានឃើញ នាង ក្នុង គ្រាភ្ជាមៗ នេះ ខ្ញុំក៏កើតចិត្តស្រឡាញ់នាងដែរ , ស្រឡាញ់អស្ចារ្យ , ចិត្តស្រឡាញ់ខ្ញុំ កើតមក ពីព្រលឹង ,

មនោវិញ្ញាណ ហើយប្ដេជ្ញាចិត្ត ថា ៖ បើមិនបាន នាងរោហិណីជា អគ្គមហេសី ទេ , ខ្ញុំមុខ ជាស្លាប់ ក្នុងទីនេះ ,ក្នុងពេលនេះ ,និងក្នុងគ្រាឥឡូវនេះឯង ។ ផ្ទុយទៅវិញបើ ជីវិតខ្ញុំនៅរស់ , ខ្ញុំនិងបានឃើញ មុខ អ្នកទាំងអស់គ្នា តទៅទៀត ។ ទេវតាទាំងបួន ក៏ដកខ្លួន , ដកពាក្យបណ្ដឹង រៀងៗខ្លួន និងទុក ឱកាសដល់ព្រះឥន្ទ្រសំរួលកិច្ច ។ ហេតុតែបុណ្យនាងធំខ្ពស់ , នាងរោហិណី ក៏ឡើងជា អគ្គមហេសី នៃព្រះឥន្ទ្រ ៕

Références ឯកសារយោង 1)អានិសង្ស30 ,ចាប ពិន ។ អានិសង្សកថា ,ឃិនវង់ ។ 2) វចនានុក្រមជួនណាត ។ គុណធម៌ដែលមានដំណើរចម្រើន=ដំណើរធ្វើឱ្យចំរើន ។ គុណធម៌=សេចក្ដីសុខ និង សេចក្ដីទុក្ខ តាមជាន់តាមថ្នាក់ បានខាងអំពើល្អ-អាក្រក់ ពោលគឺបុណ្យ-បាប ។

Annexe ឧបសម្ពន្ធ ។ កាលពីថ្ងៃ១៧ កុម្ភៈ ២០១៩ វត្តពោធិវង្ស បានរៀបចំឆ្លងឃ្លាំងសាលា ទុកជា គរុភ័ណ្ឌ ។ ការសាងសង់កុដិសម្ភារៈ ជាថ្មីនេះ ស្ថិតនៅក្រោមការគ្រប់គ្រងលោក ហេង គីម និងការចូលរួម ភិក្ខុទាំងឡាយ និង ឧបាសក ឧបាសិកា ជើងវត្ត ។ កុដិសម្ភារៈ នេះ សាងសង់ដោយបច្ច័យរបស់វត្ត និងអំណោយ របស់ពុទ្ធបរិស័ទ មានជាអាទិ លោកស្រីវេជ្ជបណ្ឌិត លីម កែវ វណ្ណា និងលោកវេជ្ជបណ្ឌិត យូ ផូនថៃ, ឧបាសិកា Lim Sauv Thung ព្រមទាំងគ្រួសារ ។















ខេត ប៊ុនថាក់ណា

# ABHIṆHA PACCAVEKKHAṆA

# IDÉES DEVANT ÊTRE FRÉQUEMMENT CONTEMPLÉES

# MOYENS POUR SE DÉBARRASSER DES POLLUTIONS MENTALES(KILÉSAS)

# PAHĀNA=5

Les moyens pour se débarrasser des conditions malsaines, (appelés en pali Pahāna) sont au nombre de 5 :

1-Vikkhambhana Pahāna : abandon des kilésas par élimination. Les gens qui pratiquent le calme mental, au moment où il entre en absorption peuvent éliminer temporairement les 5 obstacles (nīvaraṇa).

2- TadaṅgaPahāna : abandon des kilésas par opposition. Par exemple : on vainc la violence par la non-violence, l'avarice par la générosité, le mensonge par la vérité et l'attachement au soi par la réflexion et la compréhension sur le non soi. Comme dans le premier moyen, l'éradication est aussi transitoire.

3-Samuccheda Pahāna : abandon des kilesas par l'atteinte du chemin. Au moment où l'on atteint le niveau supramondain, dépassant ou transcendant le monde (lokuttaramagga), suite au développement mental(vipassana), tous les kilésas sont éradiqués.

4-Paṭipassaddhi Pahāna : abandon des kilésas par l'atteinte dulokuttaraphala. Le méditant est dans un état de calme mental.

5-Nissaraṇa Pahāna : Abandon des kilésas par l'atteinte du nibbāna. Tous les kilésas sont définitivement et complètement éradiqués.

Les gens ordinaires (Puthujjana) ne peuvent pas éradiqués complètement les kilésas. Tout au plus ils peuvent atteindre les 2 premiers niveaux. Ils peuvent abandonner ou calmer temporairement les kilésas au moment de leur pratique, mais ces souillures peuvent réapparaitre. Pourquoi les gens ordinaires ne peuvent-ils pas abandonner complètement les kilésas ? Parce qu'ils n'ont pas assez de sagesse, de clairvoyance et n'ont pas une farouche détermination pour pouvoir les éradiquer.

NB : il existe 2 sortes de Puthujjana :

a- KalyāṇaPuthujjana : les gens ordinaires qui, bien qu'étant pollués par les souillures, comprennent les lois de cause et effet du dhamma.
b- AnthāPuthujjana : les gens ordinaires qui ne connaissent pas les lois de cause et effet et qui sont aveuglés complétement par les souillures.

## LOKUTTARA MAGGA

Les quatre sentiers avec leurs fruits

Selon le degré d'éveil par lequel un certain nombre de souillures mentales(SAṀYOJANA) sont éradiquées, on peut classer les pratiquants spirituels en quatre niveaux :
1-Sotāpattimaggañāṇa : Sotāpuggula peut annihiler les trois premiers liens : Sakkāyaditthi, Vicikiccā,Sīlabbataparāmāsa et les 2 anusayas : Diṭṭhānusaya et Vicikiccānusaya.
2-Sakadāgāmimaggañāṇa : Sakadāgāmipuggula n'a pas éradiqué d'autres liens en plus de ces 3 premiers, mais il a pu affaiblir l'avidité, la colère et l'illusion. En outre il a pu aussi affaiblir les 2 autres anusayas :Kāmarāgānusaya et Paṭighānusaya.
3-Anāgāmimaggañaṇa :Anāgāmipuggula peut annihiler 2 autres liens : Kāmarāga et paṭigha et éradiquer définitivement et complètement :Kāmarāgānusaya et Paṭighānusaya.
4-Arahattamaggañāṇa : arahantapuggula peut annihiler complètement tous les liens restants :Rūparāga, Arūparāga, Māna, Uddhacca et Avijjā ainsi que les 3 autres anusayas :Mānānusaya,Bhavarāgānusaya et Avijjānusaya.

## ADHIṬṬHĀNA

C'est l'une des 10 vertus transcendantes (pāramī) recommandées par le Bouddha aux pratiquants qui veulent atteindre l'éveil.Adhiṭṭhāna veut dire résolution, implication, engagement et détermination.C'est la ferme détermination de quelqu'un qui veut atteindre un but précis, sans hésitation. Tout pratiquant doit posséder cette vertu. Par exemple, il doit être déterminer à faire la méditation de 10 minutes ou même plus tous les jours. Une fois décidée, il faut qu'il respecte scrupuleusement cette détermination. C'est cette résolution qui fait qu'on puisse réussir et atteindre son objectif. La pratique à la légère « comme l'a dit un dicton khmer : la pratique comme un feu de paille », ne mène nulle part. Quand on entreprend un important projet, il faut avoir une ferme résolution. Le Bouddha, avant son éveil, s'est déterminé à rester méditer au pied de l'arbre, quitte à mourir dans cet endroit, s'il ne pourra pas trouver la vérité et atteindre Nibbāna. Le pratiquant bouddhique doit posséder cette ferme détermination, s'il veut annihiler tous les kilésas. Ce ne sont pas ni le maître, ni le lieu ni les doctrines de tels ou tels enseignants qui lui apportent la réussite. Mais c'est sa détermination et sa pratique, selon les enseignements du Bouddha, qui font son succès. La pratique de l'abhiṇhapaccavekkhaṇa est largement suffisante, car on y trouve le triple caractéristique de la vie : l'impermanence, la souffrance et le non soi. On y trouve également les enseignements sur les causes et effets (Kamma et phala). En plus de la détermination, il y a encore 6 facteurs favorisant qui peuvent aider le pratiquant à atteindre son but. Ce sont :
1- la foi (=confiance fondée sur la connaissance, une certaine dose de sagesse), 2-HIRI= la honte de faire des mauvaises actions 3-Ottapa= la crainte de faire des mauvaises actions,4-Viriya=la vigilance, 5-Paññā= la sagesse(=connaissance transcendante qui permet d'aller au-delà des apparences) et 6-le sacrifice (on n'hésite pas à tout abandonner même sa vie pour atteindre son but). Le pratiquant spirituel doit être conscient de cette notion de sacrifice.

Le fait d'être conscient régulièrement de la mortpeut- il apporter un préjudice quelconque ?
Les gens ordinaires qui n'ont pas appris à connaitre ces 5 abhiṇha, pensent, à l'instar des nobles êtres, que le fait de penser à la mort peuvent causer des infortunes. Ils raisonnent ainsi : il est inutile de penser à ces 5 idées fondamentales. Que l'on pense à ces 5 choses ou non, elles finissent par nous arriver. Donc il est inutile de perdre son temps à méditer sur ces idées fondamentales. Certaines de ces gens dépensent leur temps et leur fortune inconsciemment et inconsidérément dans la joie et dans des mauvaises actions. Ils pensent aussi qu'aucune de ces 5 choses ne puissent pas leur arriver.

Mais le jour où ils auront rencontré la séparation ou la mort dans leur vie etc.., ils souffriront plus que les autres personnes. Certaines autres personnes ont la bonne fortune de naître dans une bonne famille. Ils mènent une vie facile sans penser à accomplir des bonnes actions. « Dans le bouddhisme, on dit qu'ils vivent aux dépens de leur ancien karma (c'est-à-dire ce sont leurs anciennes actions dans leur ancienne vie qui procurent leur fortune actuelle) ». Il existe 4 sortes de personnes :

1- Les gens qui naissent dans l'ombre et disparaissent dans l'ombre,
2- Les gens qui naissent dans l'ombre et qui disparaissent dans la lumière,
3- Les gens qui naissent dans la lumière et disparaissent dans l'ombre,
4- Les gens qui naissent dans l'ombre et qui disparaissent dans la lumière.

NB : l'ombre désigne ici les mauvaises actions et leur conséquence néfaste, naître dans l'ombre veut dire naître dans une famille pauvre ou naître avec un handicap quelconque, sans intelligence. Disparaitre dans l'ombre veut dire quitter ce monde après avoir accomplir des mauvaises actions et sans avoir accomplir une ou plusieurs bonnes actions. Lumière désigne les bonnes actions et leur conséquence. Naître dans la lumière veut dire naître dans une bonne famille avec une bonne apparence physique et c'est une personne intelligente. Disparaître dans la lumière veut dire quitter ce monde après avoir accomplir des actions bénéfiques pour leur famille et pour la société. Ils évitent d'accomplir les mauvaises actions.

## MARAṆĀNUSSATI

Méditation sur la mort consiste à garder à l'esprit le caractère inéluctable de la mort afin de ne pas être grisé par les plaisirs non permanents.

Le Bouddha a dit : O ! bhikkus, le fait de penser et de développer incessamment maraṇānussati apporte beaucoup de mérites et de conditions pour échapper de la souffrance et pour se rapprocher du Nibbāna.

Pourquoi certaines personnes pensent, au contraire, que le fait de penser à la mort peut apporter les infortunes ? C'est parce qu'ils pensent à la mort de quelqu'un qui leur est proche ou à leur propre mort. Ils paniquent devant cette perspective, ils souffrent en pensant à cette possibilité. Mais au contraire, s'ils méditent régulièrement sur la mort, ils savent que la mort peut survenir à tout moment, qu'on le veuille ou non, par un accident, par une maladie qui sont parfois sans gravité. Elle peut arriver à tout le monde : riche ou pauvre, dans une grande maison ou dans un taudis, sur terre, sur mer ou dans l'air. Pensant ainsi, ils développent leur compréhension sur la naissance, la décrépitude et la mort et ils voient l'urgence de développer les bonnes actions et d'éviter de faire des mauvaises actions. Quand on sait qu'une chose est inévitable et naturelle, quand cette chose arrivera, on souffrira moins. On peut comparer les gens qui négligent de méditer sur les 5 idées fondamentales à quelqu'un qui n'a pas été vacciné contre une maladie. Quand il est atteint par cette maladie, il n'a pas d'anticorps pour se protéger. Par contre quand on a l'habitude de réfléchir à ces idées fondamentales, on sait qu'un jour la maladie, la vieillesse, la séparation, la mort ou le kamma peut lui arriver inévitablement, insidieusement ou brutalement. Ce n'est pas parce que nous méditons de

temps en temps à ces 5 idées, qu'elles vont nous atteindre. Si c'était aussi simple et facile à réaliser, on aurait qu'à penser à gagner au loto, à devenir riche ou à devenir un haut fonctionnaire. De toute façon, il y a des gens qui ne pensent pas à la mort et qui, meurent prématurément. Il y a des gens qui méditent souvent sur la mort et qui meurent vieux. Il y a des gens qui pensent à la mort et qui meurent jeunes ou au contraire des gens qui n'y pensent pas et qui meurent vieux. Donc ce n'est pas le fait de penser ou de ne pas penser qui provoque la mort. La mort est inévitable imprévisible et incertaine. La différence c'est le degré de souffrance personnelle.

## KAMMA ou ACTION

Toutes les actions, qu'elles soient physiques (kāyakamma), verbales (vacikamma) ou mentales (manokamma) sont appelées kamma. Les bonnes actions sont appelées kusalakamma ou puññakamma (actions positives) et les mauvaises actions sont appelées akusalakamma ou pāpakamma (actions négatives). Toute action volontaire, consciemment acceptée et accomplie physiquement, verbalement et mentalement est appelée Kamma. **Donc kamma désigne la volonté de faire ou d'accomplir un acte.** En fonction du degré de la volonté, un acte apporte plus ou moins de résultat.

Kamma est une loi naturelle. C'est la loi de causalité, de causes et d'effets, le kamma, est juste et équitable. Kamma n'est sous le contrôle de personne. Il n'est influencé ni par l'amour ni la haine, par une personne, par un dieu quelconque, par la peur ou par la soumission. On peut comparer Kamma au feu. Le feu brûle tout : les êtres, les animaux, les objets vivants ou non, propres ou sales. Il brûle tout, car c'est sa nature de tout brûler. Kamma, comme le feu, juge tout le monde de la même manière. Que vous soyez puissant ou faible, riche ou pauvre, tant que vous faites des mauvaises actions, vous récolterez de mauvaises conséquences. Au contraire, si vous faites des bonnes actions, vous serez récompensés. Mais il y a une petite nuance à laquelle il faut faire attention. Dans Kamma, il y a la notion de volonté. Il y a une différence entre une action volontaire et une action non volontaire. Une action volontaire a beaucoup plus de conséquences qu'une action non volontaire.

Kamma est la propriété de celui qui l'a accompli et il est pour toujours, dans cette vie et dans la vie ultérieure. On peut profiter de sa richesse dans cette vie, mais on ne peut pas l'emporter avec soi dans l'autre monde. Au contraire Kamma vous suit partout, dans ce monde ou dans la vie ultérieure. Il appartient à celui qui accomplit l'acte. On ne peut pas dire par exemple: je vais tuer quelqu'un, mais c'est à un tel de recevoir la punition à ma place.

Kammadāyāda : on est l'héritier des conséquences de ses actions. On récolte ce qu'on a semé. Dans le monde mondain, il se peut qu'il y ait des gens qui profitent du travail des autres : les dictateurs, les escrocs, les gens malhonnêtes. Dans kamma, personne ne peut échapper des effets de ses actions.

On ne peut pas dire à quelqu'un : ne t'inquiètes pas, tu peux voler, tuer, c'est moi qui vais recevoir toutes les punitions à ta place. Dans Kamma, il n'y a pas de favoritisme, ni d'injustice et ni de corruption.

Kamma yoni : Kamma est à l'origine de chaque être : celui qui cultive les plantes, on les appelle les cultivateurs, celui qui vole, on l'appelle le voleur, etc... C'est kamma qui fait que l'on nait dans un monde meilleur ou dans des états infernaux.

Kammabandhu : kamma est un parent ou allié (=bandhu). Dans la vie, quand on a un problème quelconque, on peut faire appel à la famille ou aux amis proches ou lointains. Mais ce n'est pas toujours possible. La famille, les amis proches ou lointains, la fortune et les possessions nous sont utiles que dans cette vie. Dans la vie ultérieure, nous ne pourrons pas les apporter avec nous. Alors que kamma, n'oublie jamais ceux qui l'ont compris et accepté. Il sera toujours présent à leurs côtés. Il les suivra partout. Kamma est un véritable allié.

Kamma comme protection : Dans cette vie ou dans la vie ultérieure, on peut compter sur son kamma. On mène une vie honnête et laborieuse, on est sûr de pouvoir compter sur les bons résultats de ces bonnes actions. Celui qui fait une action, qu'elle soit bonne ou mauvaise, celui-là est sûr de recevoir un résultat en fonction de ses actions.

## VAṬṬA : SAṂSĀRA, cycle de renaissances, continuité ou cercle, succession

Nous avons vu que Kamma joue un rôle important dans la vie présente et ultérieure de chaque personne. Kamma fait donc partie de la chaine de la production conditionnée du saṁsāra, c'est-à-dire du cycle de renaissances de chaque être.

Dans cette origine interdépendante ou conditionnée (Paṭiccasamupāda), il y a des facteurs qui se regroupent en 3 cycles :

a- Le cycle de Kamma (kamma-vaṭṭa) comprenant les formations de kamma et le processus de kamma (saṅkhāra) qui sont responsables des conditions de la renaissance.
b- Le cycle de souillures (kilesa-vaṭṭa) comprenant : l'ignorance (avijjā), le désir (ṭaṇhā) et l'attachement (Upādāna) qui sont responsable de la renaissance.
c- Le cycle des résultats (vipāka- vaṭṭa), comprenant : la conscience (viññāṇa), la corporéité et la mentalité (nāma-rūpa), les six bases (salāyatana), le contact (phassa), les sensations (vedanā), processus de devenir(bhava), la renaissance (jāti) et finalement la vieillesse et la mort (jarā-maraṇa).

Un petit rappel sur l'origine conditionnée : Paṭiccasamupāda; A l'origine il y a l'ignorance.

a- avijjā entraine l'apparition saṅkhāra,
b- saṅkhāra---- --------------------- viññāṇa,
c- viññāṇa-------------------------- nāma-rūpa,
d- nāma-rūpa----------------------- salāyatana,
e- salāyatana------------------------ phassa,
f- phassa ---------------------------- vedanā,

g- vedanā----------------------------- ṭaṇhā,
h- ṭaṇhā ----------------------------- Upādāna,
i- Upādāna--------------------------- bhava,
j- Bhava ----------------------------- jāti,
k- Jāti--------------------------------- jarā-maraṇa.

L'origine conditionnée est un cycle infini, on ne peut donc pas dire que c'est l'ignorance qui est le début du chainon, comme on ne peut pas dire qui de l'œuf ou de la poule existe la première.

Les actions bonnes ou mauvaises accomplies par les êtres humains, donnent inévitablement un bon ou un mauvais résultat qui se voit dans cette vie ou qui entraine la renaissance de cette personne dans une vie ultérieure. Le cycle de renaissances se répète éternellement et sans fin, mais Le Bouddha a trouvé une voie qui permet aux êtres humains de pouvoir quitter ce cycle et d'atteindre la libération définitive : (Nibbāna).

## Les quatre sortes d'actions

1-Les actions noires donnent des résultats noirs,

2-Les actions blanches donnent des résultats blancs,

3-Les actions noires et blanches donnent des résultats noirs et blancs,

4-Les actions non noires et non blanches donnent des résultats non noirs et non blancs.

NB : Les actions noires : ce sont des mauvaises actions, Les résultats noirs c'est la souffrance ou la naissance dans une famille pauvre ou avec un handicap ou dans monde infernal. Les actions blanches : ce sont les bonnes actions. Les résultats blancs, c'est la bonne fortune, la bonne santé ou la naissance dans une bonne famille ou dans un monde meilleur. Les actions noires et blanches, ce sont des personnes qui accomplissent à la fois les bonnes et les mauvaises actions au cours de leur vie. Ils récoltent les deux sortes de résultats. Les actions non noires et non blanches, ce sont les actions accomplies par les nobles personnes, dans un but précis : se débarrasser de l'avidité et des mauvaises kamma et aider leurs semblables. Ces personnes ne sont pas intéressées par les bonnes ou mauvaises actions, ni par les bons ou mauvais résultats.

NB : Plusieurs doctrines parlent aussi des kamma. Mais les points de vue sont divergents :

1- Certaines doctrines demandent à leurs disciples d'accomplir les bonnes actions, mais au cas où ils font des mauvaises actions, c'est leur dieu qui supporte les mauvaises kamma à leur place. C'est leur dieu qui distribue les bonnes ou les mauvaises kamma. C'est leur dieu qui fait qu'on nait en tant que Brahma, roi, commerçant ou esclave.
2- Dans d'autres doctrines, il n'y a pas de dieu, mais elles ne parlent que des anciennes kamma. Tout dépend des anciennes actions. Elles excluent totalement les nouvelles actions, c'est-à-dire les efforts dans cette vie.
3- Dans son enseignement, le Bouddha parle aussi des Kamma. Mais il exclut Dieu, dans la distribution des résultats. Il ne parle pas que des actions anciennes. Il insiste aussi sur les

nouvelles actions. En plus il parle des moyens pour échapper à ce cercle vicieux de renaissance. C'est ainsi qu'il parle des actions non noires et des actions non blanches et du noble sentier à 8 branches.

Puññakiriyavatthu

Sujets ou bases d'actions valorisantes

Nous avons parlé des enseignements du Bouddha sur les kamma, sur l'origine conditionnée et les différentes sortes de kamma. Nous allons parler maintenant des bases d'actions valorisantes. Pour que les bonnes actions puissent être considérées comme de véritables bonnes actions, il faut qu'elles soient accomplies dans de bonnes conditions et en respectant certaines règles. Par exemple : Vous n'avez pas d'argent et vous voulez faire des dons. Pour avoir des sous vous allez commettre des vols ou des mauvaises actions. Pour vous enrichir, vous gagnez malhonnêtement votre vie, vous pratiquez les 5 commerces proscrits par le Bouddha : commerce de femmes, d'êtres vivants, d'armes, de produits enivrants et de produits venimeux. Ces moyens de gagner des sous pour faire des dons ne sont pas bons. Donc ces actes ne peuvent pas être considérés comme des actes bons.

## Les 3 sortes de bases d'actions valorisantes

1-Dānamaya puññakiriyavaṭṭhu : pratique du don.

2-Sîlamaya puññakiriyavaṭṭhu : pratique de la conduite éthique.

3-Bhāvanāmaya puññakiriyavaṭṭhu : pratique du développement mental.

Définition de Puñña (bonn en langue khmère) :3

1-Action vertueuse, mérite,

2-Toute action purifiante le mental, c'est-à-dire l'élevant vers des états sains et bénéfiques,

3-Accumulation de bienfaits résultant de la pratique du Dhamma.

**Dānamayapuññakiriyavaṭṭhu** : On fait des dons, on récolte les mérites. Pourquoi doit-on pratiquer les dons : C'est pour :

1-Donner de l'argent ou de la nourriture aux gens qui sont dans le besoin,

2-Témoigner sa reconnaissance à ses parents, aux bienfaiteurs ou aux gens qui ont fait des actions nobles ou à des œuvres caritatives,

3-Eradiquer son avarice. Le don est un des 10 pāramī (qualités ou vertus transcendantes) recommandées par le Bouddha à ceux qui aspirent à l'éveil.

On peut pratiquer le don à tout moment. On peut faire des dons avec le peu de choses qu'on possède, même avec une bouchée de riz. L'essentiel c'est de partager et d'aider. On peut fait des dons en nature : aider physiquement les handicapés, les personnes âgées etc. On peut aussi faire

des dons immatériels, par exemple : donner des conseils, expliquer ou aider les gens à comprendre les enseignements du Bouddha. Mais éviter de s'imposer ou forcer les gens à faire selon notre opinion.

Mais il faut faire attention dans la manière de donner. On ne fait pas n'importe quoi ou n'importe commun. Il faut savoir donner, donner avec sagesse, sinon on peut se faire arnaquer par des gens malintentionnés. Dans ce cas le don est considéré comme un encouragement aux gens malhonnêtes.

**Sîlamayapuññakiriyavaṭṭhu :**

La pratique des éthiques moraux apporte beaucoup de mérites. On essaie de maitriser et de contrôler nos organes des sens. On évite de commettre des mauvaises actions qu'elles soient manuelles (kāyakamma), verbales (vacīkamma) ou mentales (manokamma). Pour pouvoir maitriser les organes des sens, il faut que notre mental (sati) soit toujours conscient de tous les faits et gestes. Il y a plusieurs niveaux de préceptes selon les pratiquants. Mais tout au moins il faut pratiquer les 5 préceptes de base qui sont déjà suffisants pour éviter les 10 mauvaises actions. Les 5 préceptes sont :

1- Eviter d'ôter la vie des êtres vivants,
2- Eviter de voler les objets des gens,
3- Eviter de pratiquer l'adultère,
4- Eviter de dire des mensonges,
5- Eviter de consommer des produits enivrants et intoxicants.

Pratiquer les préceptes veut dire : c'est la volonté d'éviter de commettre :

- les 3 mauvais actes physiques : tuer, voler les objets des autres personnes, et pratiquer l'adultère,

-les 4 mauvais actes verbaux : le mensonge, la calomnie, la grossièreté et les paroles inutiles,

-les 3 actes mentaux : l'avidité, la colère et l'ignorance ou l'illusion.

Les préceptes sont considérés comme la fondation d'un édifice. Sans les préceptes, le don et le développement mental ne peuvent pas donner de bons résultats.

**Bhāvanāmayapuññakiriyavaṭṭhu :** Le développement mental joue un rôle très important dans le contrôle des organes des sens (Indrya). Sans la maitrise de ces derniers, on ne peut pas contrôler les actes physiques, verbaux et mentaux. Le mental dirige et commande tous les actes. En effet toutes les volontés sont nées dans le mental. Des mauvaises pensées apparaissent des mauvaises actions et des bonnes pensées apparaissent des bonnes actions. Un esprit non apprivoisé, dominé par l'avidité, la colère et l'ignorance n'entraine que l'apparition des mauvaises actions. Il nous crée, dans ce cas, beaucoup de dangers, plus que nos ennemis encore. Il crée des ennemis pour nous. Par contre un esprit bien éduqué, nous rend beaucoup plus de service ou de bienfaits plus que nos parents encore. Le développement mental est le seul chemin qui nous permet d'échapper du cycle

de renaissance sans fin et d'atteindre la libération. Les personnes qui veulent acquérir une bonne forme physique, la richesse et l'intelligence doivent pratiquer assidument les trois puññakiriyavaṭṭhu.

Le développement mental

Un mental bien apprivoisé est source de paix

Il existe 2 sortes de développement mental :

1-Samatha bhāvanā : Développement du calme mental,

2-Vipassanābhāvanā : Développement de la vision pénétrante ou de la sagesse.

Etat du mental : C'est le mental qui reconnait et qui reçoit tous les objets mentaux. Quand il est en contact avec les objets agréables, il se réjouit. Par contre s'il reçoit les sensations désagréables, il s'attriste ou même il se met en colère. Mais quand il est en contact avec quelque chose qui n'est ni agréable, ni désagréable, il est neutre.

Le mental est inconstant et instable. Il passe la journée à courir après les sensations agréables et à rejeter les sensations désagréables. Un mental, non apprivoisé, se comporte comme un animal dans une cage. Par contre un mental apprivoisé n'apporte que les avantages et est source du bonheur. On peut apprivoiser le mental en pratiquant le développement mental.

**Les 6 objets mentaux : Ārammaṇa**

Sphère des stimulus sensoriels ou organes des sens

1-Rūpārammaṇa : forme matérielle,
2-Saddārammaṇa : son,
3-Gandhārammaṇa : odeur,
4-Rasārammaṇa : saveur,
5-Phassārammaṇa : contact,
6-Dhammārammaṇa : pensée, notion.

**Les 6 portes d'entrée des objets mentaux : Dvāra-ārammaṇa**

1-Cakkhu Dvāra : les yeux,
2-SotaDvāra : les oreilles,
3-GhaṇaDvāra : le nez,
4-Jivha Dvāra : la langue,
5-KayaDvāra : le corps (la peau),
6-ManoDvāra : la pensée.

**A Suivre**

ង៉ី ហុក NGY Hok

1

# អរិយបុគ្គល ៨ ថ្នាក់ ឬ ៨ ជាន់

ភិក្ខុទាំងឡាយ ដូចម្តេច ភិក្ខុ ទើបឈ្មោះថា ដល់នូវភាពជា**អរិយៈ** ។ ភិក្ខុក្នុងធម៌វិន័យនេះ រមែងដឹងច្បាស់តាមពិតថា *នេះទុក្ខ នេះទុក្ខសមុទ័យ* (ហេតុឲ្យកើតទុក្ខ) *នេះទុក្ខនិរោធ* ( រំលត់ទុក្ខ) *នេះទុក្ខនិរោធគាមិនីបដិបទា* (ផ្លូវបដិបត្តិរំលត់ទុក្ខ)។

អរិយៈជាបុគ្គលប្រសើរ ( Nobles ) គឺថា ជាអ្នកបានសម្រេចធម៌វិសេស។ ភិក្ខុទាំងឡាយ យ៉ាងនេះហើយ ភិក្ខុទើបឈ្មោះថា ដល់ភាពជា **អរិយៈ ។ បិដក៨៣ ទំព័រ១០៦។**

ព្រះអរិយៈមាន៨ថ្នាក់ ៖

**១- សោតាបន្ន** ( ថ្នាក់ដំបូង) ប្រែថា ជាអ្នកដល់នូវក្រសែ គឺថាបានសម្រេច សោតាបត្តិផលហើយ( កើតទៀតយ៉ាងច្រើន៧ជាតិ ឬ៧ដងទៀតប៉ុណ្ណោះ)។

**២- សកទាគាមិ** ប្រែថាជាអ្នកត្រឡប់មកតែម្តងទៀតប៉ុណ្ណោះ គឺបានសម្រេច សកទាគាមិផលហើយ។

**៣- អនាគាមិ** ប្រែថាជាអ្នកមិនត្រឡប់មកទៀតទេ គឺបានសម្រេច អនាគាមិផល ហើយ។

**៤- អរហន្ត** (ថ្នាក់ខ្ពស់បំផុត) ប្រែថាជាអ្នកគួរ ឬអ្នកបានកាច់បំបាក់សង្សារ (សង្សារ គឺការវិលវល់ទៅក្នុងភពគឺកើតស្លាប់ៗមិនចប់ គឺថា អស់ភពហើយ ឬថាមិនកើតទៀតឡើយ) គឺបានសម្រេចអរហត្តផលហើយ។

## **អរិយសច្ចៈ** ( Nobles Vérités )

សេចក្តីពិតដ៏ប្រសើរ សេចក្តីពិតដែលធ្វើឲ្យអ្នកចូលដល់ទៅជា**អរិយៈ**។

**បិដក លេខ៧ទំព័រ ៣១៤**

( ១២៤ ) ការអន្ទោលទៅកាន់ផ្លូវឆ្ងាយ ក្នុងជាតិទាំងឡាយនោះៗឯង ព្រោះមិនបានឃើញតាមពិត នូវ អរិយសច្ចៈទាំង៤ ។ អរិយសច្ចៈទាំង៤នេះឯង តថាគត និង អ្នកទាំងឡាយ បានឃើញហើយ តណ្ហានាំទៅកាន់ភព តថាគត និង អ្នកទាំងឡាយ បានគាស់រំលើងហើយ ឫសនៃសេចក្តីទុក្ខ ក៏ តថាគត និង អ្នកទាំងឡាយ ផ្តាច់ចោលហើយ ឥឡូវនេះ គ្មានភពថ្មីទៀតទេ។

## ឥន្ទ្រិយ៥ + អរិយបុគ្គល ៨

(**ឥន្ទ្រិយ**គឺភាពជាធំក្នុងកិច្ចឬនាទីរបស់ខ្លួន ក្នុងទីនេះគឺភាពជាធំក្នុងការត្រាស់ដឹង)

**(២១១)** ភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន៥ប្រការ គឺ ១-សទ្ធិន្ទ្រិយ=ឥន្ទ្រិយគឺសទ្ធា (ជឿការត្រាស់ដឹងនៃព្រះពុទ្ធ),២-វិរិយិន្ទ្រិយ=ឥន្ទ្រិយគឺព្យាយាម, ៣-សតិន្ទ្រិយ= ឥន្ទ្រិយគឺស្មារតី(ឬរំលឹកដឹង),៤-សមាធិន្ទ្រិយ=ឥន្ទ្រិយគឺសមាធិ(ចិត្តតាំងមាំ), ៥-បញ្ញិន្ទ្រិយ = ឥន្ទ្រិយគឺ បញ្ញា (ការដឹងតាមសេចក្តីពិត)។

**(២១២)** ភិក្ខុទាំងឡាយ ៖ ( **បិដកលេខ ៣៨ ទំព័រ ១៥៣** )

**១- អ្នកបដិបត្តិ ដើម្បី ធ្វើឲ្យជាក់ច្បាស់នូវ សោតាបត្តិផល** ( គឺថា **សោតាបត្តិមគ្គ** )
ព្រោះមាន ឥន្ទ្រិយ៥ ទន់ជាង ឥន្ទ្រិយរបស់**សោតាបន្ន** ។

**២- សោតាបន្ន** ព្រោះមាន ឥន្ទ្រិយ៥ ទន់ជាង ឥន្ទ្រិយរបស់ **អ្នកបដិបត្តិ ដើម្បី ធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល** ។

**៣- អ្នកបដិបត្តិ ដើម្បី ធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល** ( គឺថា **សកទាគាមិមគ្គ** )
ព្រោះមាន ឥន្ទ្រិយ៥ ទន់ជាង ឥន្ទ្រិយរបស់ **សកទាគាមី** ។

**៤- សកទាគាមី** ព្រោះមាន ឥន្ទ្រិយ៥ ទន់ជាង ឥន្ទ្រិយរបស់ **អ្នកបដិបត្តិ ដើម្បី ធ្វើឲ្យជាក់ច្បាស់នូវអនាគាមីផល** ។

**៥- អ្នកបដិបត្តិ ដើម្បី ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល** ( គឺថា **អនាគាមិមគ្គ** )
ព្រោះមាន ឥន្ទ្រិយ៥ ទន់ជាង ឥន្ទ្រិយរបស់ **អនាគាមី** ។

**៦- អនាគាមី** ព្រោះមាន ឥន្ទ្រិយ៥ ទន់ជាង ឥន្ទ្រិយរបស់ **អ្នកបដិបត្តិ ដើម្បី ធ្វើឲ្យជាក់ច្បាស់នូវ អរហត្តផល** ។

**៧- អ្នកបដិបត្តិ ដើម្បី ធ្វើឲ្យជាក់ច្បាស់នូវ អរហត្តផល** ( គឺថា **អរហត្តមគ្គ** )
ព្រោះមាន ឥន្ទ្រិយ៥ ទន់ជាង ឥន្ទ្រិយរបស់ **អរហន្ត** ។

**៨- អរហន្ត** ព្រោះមាន ឥន្ទ្រិយ៥ **ពេញលេញបរិបូណ៌** ។

ភិក្ខុទាំងឡាយ ឥន្ទ្រិយ៥នេះ មិនមានដល់ភិក្ខុណា ដោយបរិបូណ៌គ្រប់ទេ តថាគតហៅភិក្ខុនោះថាជាអ្នកស្ថិតនៅក្នុងពួក**បុថុជ្ជន** ។

**អរិយបុគ្គល ២ យ៉ាង:**

បុគ្គលប្រសើរ(អរិយៈ) អ្នកសម្រេចធម៌ពិសេស តាំងតែ សោតាបត្តិមគ្គឡើងទៅ។

**១- សេខ:** អ្នកត្រូវសិក្សាទៀត បានដល់ព្រះអរិយបុគ្គល៧ ខាងដើមនៃចំនួន៨

**២- អសេខ:** អ្នកដែលមិនត្រូវសិក្សាទៀត បានដល់អ្នកសម្រេចអរហត្តផលហើយ។

3 **សំយោជន៍ ១០ បិដក លេខ ៥០ ទំព័រ ៣៦**

**សំយោជន៍** គឺ ធម្មជាតិដែលចងសត្វទុកក្នុងវដ្ត(វដ្តគឺការវិលវល់ស្លាប់កើត)

(១៣) ភិក្ខុទាំងឡាយ សំយោជនៈ ១០ប្រការនេះគឺ៖

***ក- ឱរម្ភាគិយសំយោជនៈ*** *(សំយោជន៍ខាងក្រោម-ថ្នាក់ទាប) មាន៥៖*

**១- សក្កាយទិដ្ឋិ:** ឃើញខុសថាកាយ(ខន្ធ៥) ជាតួខ្លួន

**២- វិចិកិច្ឆា:** សេចក្តីសង្ស័យ

**៣- សីលព្វតបរាមាស:** គឺស្ទាបអង្អែលសីលនិងវត្ត(វត្តគឺការប្រព្រឹត្តិតាមទម្លាប់)

**៤- កាមឆន្ទ:** ឬ **កាមរាគ:** គឺ ខ្វល់ខ្វាយក្នុងកាម ឬ ការត្រេកត្រអាលក្នុងកាម

**៥- ព្យាបាទ** ឬ **បដិឃ:** គឺមិនពេញចិត្ត គឺចិត្តខឹង

***ខ- ឧទ្ធម្ភាគិយសំយោជនៈ*** *(សំយោជន៍ខាងលើ-ថ្នាក់ខ្ពស់) មាន៥៖*

**១- រូបរាគ:** រូបភព (ភពគឺជាទីកើតនៃអ្នកមានឈាន(Jhana)គឺព្រហ្មមានរូប(១៦)

**២- អរូបរាគ:** អរូបភព(ភពគឺជាទីកើតនៃអ្នកមានឈានខ្ពស់)គឺព្រហ្មគ្មានរូប(៤)

**៣- មាន:** គឺមាន:(ការប្រកាន់ខ្លួនថាប្រសើរជាង,ឬស្មើគ្នា,ឬទាបជាង) (orgueil)

**៤- ឧទ្ធច្ច:** គឺ ចិត្តរាយមាយ

**៥- អវិជ្ជា** គឺ សេចក្តីល្ងង់ខ្លៅមិនដឹងអរិយសច្ច:។

**មគ្គ ៤**

មគ្គគឺផ្លូវចូលទៅដល់ភាពជាអរិយបុគ្គល គឺញាណ(បញ្ញាជាលោកុត្តរ:) ដែលធ្វើឲ្យលះសំយោជន៍បានដាច់ខាត។ (លោកុត្តរ:ធម៌៩ជាធម៌ធ្វើសត្វឲ្យឆ្លងផុតចាកលោក)៖

**១- សោតាបត្តមគ្គ ៖** មគ្គដែលធ្វើឲ្យដល់ភាពជា **សោតាបន្ន** ជាហេតុឲ្យលះ
សំយោជន៍បាន៣ គឺ សក្កាយទិដ្ឋិ , វិចិកិច្ឆា , និង សីលព្វតបរាមាស:

**២- សកទាគាមគ្គ ៖** មគ្គដែលធ្វើឲ្យដល់ភាពជា **សកទាគាមី** ជាហេតុឲ្យលះ
សំយោជន៍បាន៣ដូចសោតាបន្នដែរ ថែមទាំងធ្វើ រាគ: ទោស: មោហ: ឲ្យស្រាលចុះ។

**៣- អនាគាមិមគ្គ ៖** មគ្គដែលធ្វើឲ្យដល់ភាពជា **អនាគាមី** ជាហេតុឲ្យលះ
សំយោជន៍ ខាងក្រោមបានទាំង៥។

**៤- អរហត្តមគ្គ ៖** មគ្គដែលធ្វើឲ្យដល់ភាពជា **អរហន្ត** ជាហេតុឲ្យលះសំយោជន៍
បានទាំង១០។៚ **ឈិម សាវិត 20/08/2019**

# មិត្ត នឹង អមិត្ត

១- មនុស្សដែលយើងទុកជាមិត្ត ចរិយាត្រង់ពិតគួរទុកចិត្ត
មិនចេះភូតភរមិនក្រាញស្វិត បញ្ចៀង,បញ្ចិត មិនស្វាគមន៍ ។

២- មិត្តល្អគឺមនុស្សចិត្តស្មោះត្រង់ មិនចេះវាយឫក,គ្មានគំនំ
អាចពឹងពាក់បាន ចិត្តទូលំ សប្បាយ-ព្រួយ សើច-យំ ដូចប្អូន-បង ។

៣- រកមិត្តចេះដឹង មានបញ្ញា ស្គាល់វិជ្ជាការ ច្បាស់កន្ទង
អាចជួយពន្យល់-ចង្អុលផង លើកស្ទួយចងក្រងឱ្យខ្ពង់ខ្ពស់ ។

៤- រីឯអមិត្តពិតជាខូច ល្បិចល្បៀតកំហូចអាប់កិត្តិយស
ក្រវិចក្រវង់ដូចសត្វពស់ ភូតភរ ជម្ទោះជាអលជ្ជី ។

៥- មនុស្សខ្វាច-ញ៉ាកខ្វះភ្ជាហាន មិនអាចពឹងបានជាពេញទី
គិតតែប្រយោជន៍ ខ្លួនឥន្ទ្រីយ មិនមែនគ្នាគ្នីឬម្រាក់ក្តើ ។

៦- អ្នកនិយាយច្រើន មាត់មិនជិត គឺជាអមិត្ត ឥតប្រសើរ
មិនចេះលាក់បាំង រឿងដំណើរ បង្ហោះបង្ហើរការសម្ងាត់ ។

៧- ហេតុនេះគួរយើងពិចារណា មុនប្តូរចិន្តា ហុចព្រះហត្ថ
មុនចងមិត្តភាព គួរប្រយ័ត្ន ក្រែងកើតវិបត្តិ រួចស្តាយក្រោយ ។

៨- មិត្តភាពរវាងមនុស្ស ឬ រដ្ឋ គ្មានការសង្កត់ឱ្យម្នាក់ខ្សោយ
ចំណេះ ចំណេញទីងហុចឱ្យ មិនត្រូវបណ្តោយការជ្រៀតជ្រែក ។

៩- មិត្តភាពប្រៀបដូចជាសាមគ្គី មនុស្ស-រដ្ឋទាំងពីរត្រូវវែកញែក
សន្តិភាព-សួស្តី បែកផ្កា-មែក ពេញមុខ-ពេញភ្នែកយ៉ាងប្រសើរ ។

១០- រស់នៅក្នុងលោកត្រូវមានមិត្ត ទោះនៅឆ្ងាយជិតអាចពឹងប្រើ
ជួយគ្នាទៅ-មក តាមដំណើរ ស្នងស្នៀត្រស្មោះស្មើ ទុកចិត្តគ្នា ។៚

ជេត្រ សេដ្ឋា

១៩--០៧-២០១៩

# L' H Y M N E A LA VIE AU BONHEUR



Par un bel après-midi ensoleillé
D'un dimanche 6 août 1995 je suis allée
Avec ma famille rendre visite aux enfants
De la fondation Khmère créée tout récemment

Quittant la grande route nous débouchons
En pleine campagne vers une haute maison
Entourée sur les 3 côtés par une grande véranda
Ce qui permet de découvrir l'étendue du panorama

On sent le calme la tranquillité
On respire l'air vivifiant tout en admirant la beauté
De la nature agrémentée par des palmiers innombrables
C'est un endroit idéal pour une œuvre admirable

L'accueil si chaleureux qui nous a été réservé
Par vous, Excellence, par le personnel et les enfants de ce foyer
Nous a touchés profondément
Qu'il me soit permis de vous adresser mes remerciements

Il m'a fallu très peu de temps pour me rendre compte
Que ce n'est pas simplement d'éviter la route
De donner aux orphelins un peu de bonheur
Mais c'est une preuve d'un immense amour qui habite votre cœur.

Mme le Docteur Péou ROUZOTTE – Phnom Penh - 1995

# ការសិក្សាអត្ថបទវិជ្ជា

ដោយ

បណ្ឌិត **ឃីង ហុកឌី**

*អត្ថបទវិជ្ជា គឺ វិជ្ជាលើអត្ថបទ* (science des textes) *ជាមុខវិជ្ជាសិក្សាមានលក្ខណៈជាវិទ្យាសាស្ត្រ ក្នុងករណីណា ដែលយើងសិក្សាឲ្យបានហ្មត់ចត់ ព្រោះយើងត្រូវការចំណេះដឹង ផ្នែកមុខវិជ្ជាឯទៀតៗ ក្នុងមែកជាង អក្សរសាស្ត្រ និង មនុស្សសាស្ត្រ ដើម្បីយកមកស្ទូផ្សំជាមួយ ទើបនឹងអាចមានពន្លឺពណ្ណរាយឡើងខ្ពស់ត្រដែតបាន ហើយនឹងយល់អត្ថបទដល់ជម្រៅ។ នៅពេលនោះហើយ ដែលយើងអាចចាត់ទុកការសិក្សា លើអក្សរសិល្ប៍មានលក្ខណៈបែបវិទ្យាសាស្ត្រ។*

**ក) អត្ថបទ**

*កម្រងអត្ថបទនេះជាវត្ថុសិក្សាក្នុងវិជ្ជាអក្សរសិល្ប៍ ហើយមុខវិជ្ជានេះ ត្រូវលើកយក៖*

១) *អត្ថបទដើម* (texte original)

*អត្ថបទណាដែលជាអត្ថបទដើមគេបង្អស់នោះជាអត្ថបទសំខាន់, អត្ថបទ ដែលគ្រាន់តែការចម្លងតៗ មកក្រោយមកទៀតដូចដើមខ្លះ កែប្រែខ្លះ នេះជាអត្ថបទរាយរង, ខាងអក្សរសិល្បវិទូ ត្រូវខំ ស្រាវជ្រាវ រាវរកអត្ថបទដើមគេបង្អស់មកធ្វើជាគោល។*

២) *អត្ថបទរាយរង* (texte secondaire)

*ចំពោះអក្សរសិល្ប៍ ខ្មែរ អត្ថបទ បែបនេះមានចំនួនច្រើន ព្រោះក្នុងសម័យសសាស្ត្រា ស្លឹករឹត (គឺសម័យ ខ្មែរកណ្ដាល រវាងសតវត្សទី ១៥ ដល់ ១៩) ដោយសារ ការផ្សាយ អត្ថបទជាការចម្លងតាមការចាំមាត់ ជូនកាលចម្លងដោយ*

កែសម្រួល ឬកែបន្ថែម បន្ថយ តម្រូវតាមទស្សនៈ ពេលវេលា អ្នកចម្លង នោះឯង។ ទុកជាយ៉ាងណាក៏ដោយអត្ថបទ ត្រូវ លើយកមកសិក្សាផងដែរ ដើម្បីប្រៀបធៀបទៅនឹង អត្ថបទដើម រិះរកសេចក្តីផ្លាស់ប្តូរ និង សេចក្តីថែមថយជាប្រយោជន៍និងបញ្ជាក់ យោបល់ថែមទៀត។

៣) អត្ថបទអធិប្បាយ (commentaire)

អដ្ឋកថាឬ អត្ថក្កថា (មកពីពាក្យ បាលី អត្ថ + កថា), តាមនិយមន័យ វចនានុក្រម ពុទ្ធសាសនបណ្ឌិត្យ (ទំព័រ ១៩៨៨) បញ្ជាក់ថាជា«ពាក្យអធិប្បាយសេចក្តីឲ្យងាយយល់, ពាក្យពន្យល់, វចនាធិប្បាយ, ពាក្យអធិប្បាយបាលី, គម្ពីរអធិប្បាយបាលី»ពោលគឺមាន អត្ថបទសង្ខេបតែងដោយអ្នកសិក្សាផ្នែកអំពីអ្នកនិពន្ធដើមដូចនេះតែងតែរៀបសេចក្តី ទៅតាមទស្សនៈ យោបល់យល់ចំណេះដឹងរបស់អ្នកសង្ខេបនោះមក។ អត្ថបទបែបនេះ អាចចាត់ទុកជា អត្ថបទកាយរងហើយថាជាអត្ថបទអធិប្បាយបានដែរពីព្រោះបានរៀប សេចក្តីឲ្យបានស្រួល និងស្របទៅនឹងយោបល់ផ្ទាល់របស់ខ្លួន។

ចំពោះអត្ថបទសិក្សាហើយអធិប្បាយគឺពេញជាអត្ថបទអធិប្បាយដោយបាន សិក្សារិះរៀនរៀបសេចក្តីដើម្បីពន្យល់។

អត្ថបទបែបនេះក៏ជាអត្ថបទកាយរងដែរពីព្រោះតែងតែរិះរៀនយល់និងពន្យល់ ស្របតាមចំណេះដឹងនិងយោបល់ផ្ទាល់ខ្លួន។

ប៉ុន្តែក្នុងអត្ថបទវិជ្ជាយើងក៏ត្រូវលើកយកមកជាប្រកពសិក្សាផងដែរ។ តែសំខាន់ បំផុតគឺអត្ថបទដើមពីព្រោះមានន័យសេចក្តីពិតជារបស់អ្នកនិពន្ធដើមហើយ មានរូបរាង ជាវិធីសរសេរតែងនិពន្ធអាចបង្ហាញពីពេល ពីកន្លែង សម័យប្រវត្តិនៃដើមកំណើត អត្ថ បទនោះឯងយ៉ាងណាមិញអត្ថបទចម្លងតៗគ្នាក្តី អត្ថបទបោះពុម្ពផ្សាយសម័យ បច្ចុប្បន្ន ក្តី សុទ្ធតែបានកែប្រែវិធីសរសេរ តួអក្សរ អក្ខរាវិរុទ្ធឲ្យស្របស្រួលតាមសម័យរៀង។ ខ្លួន ពោលគឺខុសពីអត្ថបទដើម ដូចនេះពុំអាច ស ឲ្យឃើញសម័យប្រវត្តិនៃអត្ថបទដើម នោះ ឡើយ។

យោបល់រួម៖

សេចក្តីទាំងនេះបញ្ជាក់គោលសំខាន់មួយក្នុងអត្ថបទវិជ្ជា, អក្សរសិល្ប៍វិជ្ជា គឺការពឹងផ្អែកលើមុខវិជ្ជាសំខាន់២យ៉ាងគឺ៖

១) វិជ្ជាប្រវត្តិសាស្ត្រ (histoire),

២) វិជ្ជានិរុត្តិសាស្ត្រ (philologie)។

ការសិក្សាតែអត្ថបទប៉ុណ្ណោះក៏នៅពុំទាន់គ្រាប់គ្រាន់ពីព្រោះអត្ថបទទាក់ទង អាស្រ័យទៅលើអ្នកតែងអត្ថបទពោលគឺអ្នកនិពន្ធ។ ដូច្នេះវត្ថុសិក្សាអត្ថបទវិជ្ជា ក្នុងអក្សរសិល្ប៍វិជ្ជា គឺអ្នកនិពន្ធ។

## ខ) អ្នកនិពន្ធ

អ្នកតែងអត្ថបទ ជា ធាតុសំខាន់មួយក្នុងអត្ថបទវិជ្ជា ហើយ ជាវត្ថុសិក្សាសំខាន់ក្នុងវិជ្ជាអក្សរសិល្ប៍។ អក្សសិល្បវិទូខ្លះឲ្យតម្លៃ ខ្លាំងពេកទៅលើអ្នកនិពន្ធ ដោយលើកយកជាតិកំណើត ក្រុមញាតិ ក្រុមគ្រួសារ ការរស់នៅ ការសិក្សាអប់រំ និង ទស្សនៈអ្នកនិពន្ធ មកស្រាវជ្រាវធ្វើជាធំបង្អស់ពីព្រោះដោយយល់ថាន័យសេចក្តីក្នុង អត្ថបទ គឺសុទ្ធតែកើតឡើងអំពីចិត្តហើយ ជារបៀបរស់នៅរបស់អ្នកនិពន្ធនោះឯងក៏ ប៉ុន្តែគប្បីត្រិះរិះបញ្ហាអ្នកនិពន្ធនេះផងពីព្រោះ៖

១) ខ្លះស្លាប់បាត់ទៅហើយ ខ្លះទៀតពុំទាន់ជាក់លាក់ជាអ្នកនិពន្ធបែនទែន ជូនកាលគ្រាន់តែជាអ្នកចម្លងបន្តគ្នាមកទៀត។ អ្នកនិពន្ធខ្លះទៀតតែងអត្ថបទផ្ទុយទៅនឹងទស្សនៈផ្ទាល់ខ្លួនក៏មានដែរ ម្យ៉ាងទៀតចិត្តគំនិតអារម្មណ៍ផ្ទាល់ខ្លួនកប់ក្នុងចិត្ត គេពុំអាចយល់ឃើញដូចអត្ថបទមែនទែននោះឡើយ។

២) អាស្រ័យហេតុនេះមានអ្នកប្រាជ្ញមួយពួកទៀត ប្រកាន់អត្ថបទ ជាធំ។ ចំពោះអត្ថបទវិជ្ជាខ្មែរ បញ្ហា អ្នកនិពន្ធ ជា ចំណោទមួយស្មុគស្មាញ ច្រើនតែពុំមានឈ្មោះកេរ្តិ៍ដំណែលអាចប្រាប់ជីវភាព ជីវប្រវត្តិបានឡើយ។

*វិជ្ជាអត្ថបទអក្សរសិល្ប៍ គប្បីឲ្យតម្លៃទៅលើអ្នកនិពន្ធ ណាដែលមានជីវភាព ចិត្ត គំនិតទស្សនៈ ទាក់ទងស្និទ្ធស្នាលទៅនឹងអត្ថបទស្នាដៃ របស់ខ្លួនផង ហើយជាពិសេស អ្នកនិពន្ធជាតំណាង និងជាកញ្ចក់ ឆ្លុះបង្ហាញ ពី ទេស ពី កាល នៃអ្នកតែងនិពន្ធ។*

*បានសេចក្តីថា ខ្លួនអ្នកនិពន្ធទៅជាវត្ថុពិសេសចំពោះវិជ្ជាអក្សរសិល្ប៍ដរាបណា ការសិក្សាជីវប្រវត្តិ អ្នកនិពន្ធនោះ បង្ហាញប្រវត្តិ និងបរិយាកាស សង្គម ជាហេតុនាំឲ្យមាន ការតែងនិពន្ធនោះឡើង។*

**ត) សង្គមបរិយាកាស**

*១) ទីកាល*

*គឺជាកាលកំណត់ពីពេលតែងនិពន្ធ, ពេលកំណើតអ្នកនិពន្ធ, ពេលថ្ងៃផលិតផល អត្ថបទ អក្សរសិល្ប៍។*

*កំណត់កាលពេលវេលា នោះមានប្រយោជន៍សំខាន់ ដើម្បីជាពន្លឺឆ្លុះមើលសម័យ ប្រវត្តិសាស្ត្រដែលនាំឲ្យស្នាដៃអ្នកនិពន្ធបានចាប់កំណើតដែលថ្ងៃផលិតឡើង។*

*២) ទីកន្លែង*

*ស្រុក ភូមិ ក្រុង ប្រទេស ទាំងនេះ ជាធាតុ សំខាន់ដែលអាចជាជំនួយ ជួយពន្យល់ អត្ថបទ គឺ ទីកន្លែងរបស់អ្នកនិពន្ធ ឬ ទីកំណើត ស្នាដៃអ្នកនិពន្ធ។*

*៣) ទីបរិយាកាស*

*គឺ ជាជីវភាពរឿងរ៉ាវផ្សេងៗ ទំនាស់ទើសទាស់ឧបសគ្គ ឬ ចម្បាំងរាំងជល់ ការប្រយុទ្ធ វិបត្តិ គ្រប់យ៉ាងរបស់អ្នកនិពន្ធ ឬ របស់សង្គមមនុស្ស ក្តីដែលទាក់ទង និង អត្ថបទ។*

*ទីបរិយាកាស ពិសេសគឺដូចជាពេលចម្បាំង ឬ វិបត្តិធំៗ ដែលនាំឲ្យមានភ្ញាក់ ស្មារតី សតិសម្បជញ្ញៈ ភ្ញាក់ខ្លួន ភ្ញាក់គំនិត។*

*យោបល់រួម*

*អត្ថបទវិជ្ជា គឺ ជាវិជ្ជាអក្សរសិល្ប៍ ដែលត្រូវ លើកធាតុទាំង៣ខាងលើនេះ គឺៈ*

*១) អត្ថបទ អក្សរសិល្ប៍ ដែលជាវត្ថុមានរូបរាងជាសិលាចារឹក,សាស្ត្រាស្លឹករឹត, ក្រាំង, សំណេរដៃលើក្រដាស, សៀវភៅបោះពុម្ព។*

*២) អ្នកនិពន្ធអត្ថបទ អក្សរសិល្ប៍ ដែលជាអ្នកដំណាងសម័យប្រវត្តិមួយ ឬ បញ្ហាមួយៗ*

*៣) បរិយាកាសសង្គម ពោលគឺ ប្រវត្តិសាស្ត្រផ្នែក វប្បធម៌ និង អរិយធម៌។*

*គន្ទិះ ទាំង ៣ នេះត្រូវលើកយកមកសិក្សាពន្យល់ ជាប់គ្នា ដូចនេះ វិជ្ជាអក្សរសិល្ប៍ ពុំមែនមុខវិជ្ជាមួយដាច់ដោយឡែកស្រឡះពីវិជ្ជាឯទៀតៗ មាន ភាសាវិជ្ជា, និរុត្តិវិជ្ជា, ប្រវត្តិវិជ្ជា, សង្គមវិជ្ជា, ទស្សនវិជ្ជា, សិល្បវិជ្ជា, សាសនាវិជ្ជា។ល។ លុះត្រាតែចេះប្រើវិជ្ជារួមគ្នា ជាពន្លឺសម្រាប់ឆ្លុះមើលធាតុទាំង៣ នៃអក្សរសិល្ប៍ គឺ អ្នកតែង, ស្នាដៃនៃអត្ថបទតែង និង បរិយាកាសសង្គមវិជ្ជា ទើបជាវិជ្ជាអក្សរសិល្ប៍អាចយល់និងពន្យល់បានខ្លះ ឬ បានហ្មត់ចត់។*

## បញ្ជីសៀវភៅខ្លះៗ

*ភាសាខ្មែរៈ*

-ឃីងហុកឌី, *តាវង៉ក*, សេចក្តីផ្តើម, អត្ថបទបកប្រែជាភាសាបារាំង, កំណត់, អត្ថបទខ្មែរតាមអក្ខរាវិរុទ្ធដើម និង អត្ថបទទំនើបតាមវចនានុក្រមពុទ្ធសាសនបណ្ឌិត្យ, បណ្ណាគារអង្គរ, ២០០៥។

-ឃីងហុកឌី, *សាស្ត្រាភមរគ្រី កាលវៃយកពណ៌សន្តំយកព្រះរាមបាន*, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៤។

-ឃីងហុកឌី, *ល្បើកអង្គរវត្ត*, អារម្ភកថានិងបោះពុម្ពដោយឃីងហុកឌី, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៦។

-ឃីងហុកឌី, *ស្នើកម្មអក្សរសិល្ប៍ចិនលើកម្ពុជានាសតវត្សទី១៩និងទី២០*, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៧

En français:

- BARTHES R., *Le degré zéro de l'écriture*, Paris, Seuil, Coll. Points, 1972.
- BREMOND Cl., *Logique du récit*, Paris, Seuil, coll. Poétique, 1973.
- CRESSOT M., *Le style et ses techniques*, Paris, Puf, 1976.
- KHING Hoc Dy, *Un auteur cambodgien et son œuvre: Le Bhogakulakumār du poète Naṅ (Fin du 18ème Début du 19ème siècle)*, Phnom Penh, Editions Angkor, 2006.
- LABLENIE E., *Recherches sur la technique des arts littéraires*, Paris, Société d'édition d'enseignement supérieur, 1962.
- MICHAUD G., *L'œuvre et ses techniques*, Paris, Nizet, coll. Connaissance de la littérature, 1957.
- MICHAUD G. (avec la collaboration de E. FRAENKEL), Introduction à une science de la littérature, Istambul, 1950.
- PROPP V., *Morphologie du conte*, Paris, Seuil, coll. Points, 1970.
- SARTRES 6.-P., *L'imaginaire*, Paris, Seuil, coll. Idées, 1971.
- SOLLERS Ph., *L'écriture et l'expérience des limites*, Paris, Seuil, coll. Points, 1978.
- TODOROV Tz., *Littérature et signification*, Paris, Larousse, coll. Langue et language, 1967.
- WELLEK R. & WARREN A., *La théorie littéraire*, Paris, Seuil, coll. Poétique, 1973.

# សប្បាយ [១] មកវត្តពោធិវង្ស

*ពាក្យសប្បាយ* Sappāya [o] *មានន័យ៧យ៉ាង ៖*

*ក-* Approprié =*ត្រូវ ។* 1-*កន្លែងសប្បាយ,* 2- *ដំណើរសប្បាយ ។*

*ខ-* Convenable=*សមរម្យ ។* 3-*ភាពសប្បាយ ,*4-*មន្ទីរឬផ្ទះសប្បាយ ។*

*គ-* Bénéfique = *ដែលឱ្យជាគុណប្រយោជន៏ ។* 5-*សប្បាយាហារ ,*6-*សប្បាយនិងសំដី, សប្បាយ និង បុគ្គល។* 7-*ឥរិយាបថសប្បាយ ។*

**ក**-Approprié =*ត្រូវ ។*

1- *សប្បាយដ្ឋាន=កន្លែងដែលនាំឱ្យសប្បាយ ។ទីកន្លែងនេះសប្បាយណាស់។ យើងដើរលេងសប្បាយ ។ យើងចង់ទៅទីនោះ ព្រោះសប្បាយខ្លួន , សប្បាយចិត្ត , និងស្រួលខ្លួន ។ ហេតុអ្វីបានជាវត្តពោធិវង្ស* [២] *នៅឆ្ងាយពីបារីស , ២០គមពីបារីស ? ឆ្ងាយមែនពិត តែចិត្តអ្នកចង់ទៅ ។ចិត្តបង្រួញផ្លូវ ។ ឆ្ងាយក្លាយជាជិត ។ បរិស័ទ មកគគ្រឹក គគ្រេងព្រោះមាន* RER, *មានឡានក្រុង, ជាជំនិះ ដឹកនាំមកដល់វត្ត ។ បើមកឡាន ,មានកន្លែងបរិបូណ៌ សំរាប់ចត ។ វត្តជាទីគាប់ចិត្ត និងមក ព្រោះជាកន្លែង គិតត្រូវ នៃអ្នកផ្តើមគំនិត បង្កើតវត្ត ,ត្រូវតាមក្បួន ធំមព្រះ ។ មកដល់ថ្ងៃនេះ វត្ត បានរីកផ្ទៃមួយជាពីរ , គួរឱ្យកោតសរសើរ ។ នេះជាផលសប្បាយទី១ , អាវាសសប្បាយ ។*

2- *ដំណើរសប្បាយ ។ ការធ្វើដំណើរបានសុខស្រួល, សុខសប្បាយ, ពុំមានអសន្តិសុខ , ភ័យព្រួយ និងចោរឆក់លួច តាមផ្លូវ ។ ភូមិស្ងាត់ ពុំសូវមានមនុស្សអ៊ូអរ ,ស្ទះចរាចរ ។ ថ្ងៃបុណ្យ តូច , ធំ សូមចតឡាន នៅចំណតផ្សារដែលនៅប្រមាណ ២០០មែត្រ ពីវត្ត ។*

**ខ**- Convenable=*សមរម្យ ។*

3- *ភាពសប្បាយ* = *ដំណើរនៃការនៅជាសុខ ។ មកដល់វត្ត , ពុទ្ធបរិស័ទ បានជួប អ្នកដើងវត្ត , ជួបព្រះសង្ឃ ,ជួបមិត្តភក្រ្ត ។ ព្រះអង្គគ្រូ ភិក្ខុ ឆឹន គេន ,លោក តែងទទួល ភ្ញៀវជានិច្ច ថ្វីបើលោក មានវ័យចំណាស់ ,ចំណាស់ច្រើនមែនទែន ដែលយើងគ្រប់គ្នា មិនបាននឹក ថាបានអាយុវែងដូចលោក ។ ព្រះអង្គមានព្រះជន្ម ៩២វស្សា ។ លោកតែងសំណេះសំណាល គ្រប់បញ្ហា ,រឿងធំម , រឿងបញ្ហាការរស់នៅ ពុទ្ធបរិស័ទ ទូទៅ , បរិស័ទម្នាក់ៗ ,រឿងធំ, រឿងតូច ,រឿងស្រុក ,រឿងជាតិ និងរឿងវត្ត ។ល។ ឯសង្ឃ ក្មេងៗ ក៏យកតម្រាប់លោកដែរ ។លោកជួយធ្វើការវត្ត ,តាមលទ្ធភាពដែលអាចធ្វើបាន មានការ*

សំអាតវត្ត, សំណង់វត្ត ,រៀបចំធ្វើបុណ្យវត្តនិងបុណ្យឯកជន ,បុណ្យផ្កា, ផ្កាសាមគ្គី ជួយស្រុកខ្មែរ និងបំណងផ្សេងៗ ។ លើសពីការសុំសីល , មានការបង្ហាត់បង្រៀនធម៌ ,បង្ហាត់សមាធិ ។ តាមកម្មវិធីខ្លី, សមាធិ មាន២ដងក្នុងមួយអាទិត្យ ។ ម្ដងៗ ការប្រតិបត្តិមាន២ម៉ោង ។ តាមកម្មវិធីវែង ,សមាធិមាន ៧ថ្ងៃក្នុង មួយខែ ។ ភាពសប្បាយនេះជាកញ្ចក់ ,បង្ហាញ នូវ ទិដ្ឋភាព ជាប្រយោជន៍ ច្រើន ធំធេងជួយ ពុទ្ធបរិស័ទឱ្យក្រេបជញ្ជក់ នូវ សីលធម៌ ទាំងឡាយ ជាឧបការគុណ ព្រះពុទ្ធ, ព្រះធម៌ ព្រះសង្ឃ ។

4- មន្ទីរ ឬផ្ទះសប្បាយ =ផ្ទះដែលស្រួលនៅ ។ តើវត្តជាទីមនោរម្យ ឬទេ ? វត្តពោធិវង្ស ជាវត្តសប្បាយ មែន ។ វត្តកកើត [២] នៅឆ្នាំ 1982 ។ វត្តពោធិវង្ស ស្អាត ,រៀបចំតាមបែប វត្តស្រុកខ្មែរ មាន ៖

4-1-1- ក្លោងទ្វារ រំលេច ដោយក្បាច់អង្គរ និង ចម្លាក់កាំកង់តំណាង មគ្គអង្គ៨ ,ធម្មចក្កប្បវត្ត ។

4-1-2- កុដិទទួលស្នាក់សង្ឃ មាន៧បន្ទប់, បណ្ណាល័យមួយ និងផ្ទះបាយមួយ ។

4-1-3- ព្រះវិហារ[២],បញ្ចុះសីមា កាលពីឆ្នាំ 2003 ។ ខាងលើ អាចទទួលភ្ញៀវ ៩០នាក់ ។ ខាងក្រោម ជា រោងពហុកិច្ចអាចទទួលភ្ញៀវ ៦០នាក់ , ជាកន្លែងហាត់រាំ ,រៀនអក្សរខ្មែរ , រៀនធម៌ ។ កន្លែងនេះនិង ក្លាយជា បណ្ណាល័យ ក្នុងពេលដ៏ខ្លី ។ ទូដាក់សៀវភៅមានហើយ , សៀវភៅ ក៏ជញ្ជូនចូលបណ្ដើរៗ ។

4-1-4- រោងបុណ្យធំ [២] សាងសង់ កាលពីឆ្នាំ 2007 ,មានព្រះបដិមា អាចទទួល ភ្ញៀវ ១៣០ នាក់ ។

4-1-5- រោងបុណ្យតូច សាងសង់ កាលពីឆ្នាំ 2013 អាចទទួលភ្ញៀវ ១៥០នាក់ ។

4-1-6- រោងស្នាក់សំរាប់អ្នកសមាធិនិង ចុងភៅ ។ រោងនេះចាស់ទ្រុឌ ទ្រោមពេកទៅហើយ ។ សព្វថ្ងៃ រោងនេះត្រូវរំលាយចោល ហើយសង់ជាថ្មី ហើយឆ្លងពីថ្ងៃ17កុម្ភៈ 2019 ហៅ កុដិសម្ភារៈ [៣] ។

4-2-1- កាលពីឆ្នាំ 2011[៤]វត្តបានជាវ ដី មានផ្ទះមួយទុកជារោងបាយ ទី២ និងសាលាឆាន់សំរាប់សង្ឃ។

4-2-2- ផ្ទះធំមួយ, ខាងលើជាកន្លែងសមាធិ [៥] ។ ខាងក្រោមជារោង បោះពុម្ព និង រោងជំនុំ អាចទទួល ភ្ញៀវ ៥០នាក់ ។ ជាសោភ័ណភាពវត្ត ,អ្នកច្បារ ថែរក្សាសួន ដាំដំណាំ មានជីរ បន្លែ ផ្សេងៗ ។ល។ វត្តជាជំរក ដ៏ល្អ ,គ្មានខ្យល់ពិសពុល ។ កុំបង្កើត ខ្យល់ពុល ខ្យល់អាក្រក់ ដោយទុកសំរាម ស្អុយមិន ចាក់ចោល ,ក្លិនផ្កាស្រពោនរលួយមិនគួរគាប់បី ។ ក្រុមសំអាតក៏មាននាទីធំមួយដែរ ។ ក្រុមនេះ ក៏ជួយ សំអាតបង្គន់ ,ទីធ្លា ,ចាក់សំរាម ,បោសសំអាតកុដិ ,រោងបុណ្យ ,កំចាត់សត្វល្អិត មានក្រឡាត ,កណ្ដុរ ជាដើម ។

ឥ- Bénéfique =ដែលជាប្រយោជន៍ ។

5- សប្បាយាហារ =អាហារដែលបរិភោគទៅនាំឱ្យស្រួលខ្លួន ។ ក្នុងរោងបុណ្យ ,វត្តមានទីតាំងទឹក ក្ដៅ,ទឹកត្រជាក់,ទឹកតែកាហ្វេ ទទួលភ្ញៀវ ។ សូមអញ្ជើញពិសា ដោយមេត្រី ។ បើមកដល់ថ្ងៃត្រង់ ,

ដោយចែដន់ ,ភ្ញៀវ អាចដោះទាល់ មួយពេល ជាមួយអ្នកចង្រ្កាន ។ ឯព្រះសង្ឃក៏ឆាន់គ្រប់គ្រាន់ ។ កំរិតគុណភាពម្ហូបក៏គ្រាន់បើតាមថ្វីដៃ ចុងភៅ ។ ឆាន់ឆ្អែត ,ឆាន់ឆ្ងាញ់ ជាការថ្នាក់ថ្នម,រក្សារបស់ចុងភៅ , ពុទ្ធបរិស័ទក្រៅវត្ត និងក្នុងវត្ត ។ ថែរក្សា សង្ឃ គ្រាន់មានសង្ឃធ្វើបុណ្យ ។ បើពុំនោះធំមពិបាក ប្រាកដ ជាមានចោទជាបញ្ហា ។ ដើររកសង្ឃធ្វើបុណ្យ ដោយវត្តគ្មានសង្ឃបំរុងទុកជូន ជារឿងចំឡែក ។ តើហេតុបែបនេះអាចមានឬទេ ? សូមគិតទាំងអស់គ្នា ។ មានពេលខ្លះភ្ញៀវយកម្ហូបឬចង្ហាន់ ទៅប្រគេន សង្ឃ ដោយប្រការផ្សេងៗ ។ ភ្ញៀវមកធ្វើបុណ្យតូច,បុណ្យធំ , បុណ្យវត្ត ជូនឪជូនម៉ែ ,ជូនតា,កូនចៅ, ញាតិសន្តាន ។ គ្រប់បុណ្យ វត្តមានចុងភៅ , មានអ្នករៀបចំ , មានអាចារ្យ,មានសង្ឃ និងមានអ្នក ជួយ សូត្រធ៌ម នៅជាគោលជំហរ ។ សុំភ្ញៀវជួយអ្នកគោលជំហរផង ។ សុំជួយរៀបតុកៅអី , ជួយជញ្ជូនចាន ទៅ ចង្រ្កាន , ជួយលាងចានទុកដាក់ ។ កុំបាយហើយដើរចេញធ្លុយ ហាក់ដូចជាមកបាយហាង ។ នេះជាទំលាប់មិនល្អ ។ វត្តគ្មានបុគ្គលិក , ប្រាក់ខែបុគ្គលិកខ្មោចក៏គ្មានដែរ ។ សុំជួយគ្នា ។ សុំជួយរក្សាគ្នា ។ សុំជួយធ្វើការទាំងអស់គ្នា ,កុំមើលបំណាំ ។ សុំជួយដាស់តឿនគ្នា កាលបើមាន អ្នកធ្វើខុសឆ្គង ។ សុំឱ្យមានចិត្តក្លាហាន និងជួយគ្នា, ជាពិសេសជួយចុងភៅ ។ចុងភៅហត់ , ចុងភៅធ្វើបាតុកម្ម ។ យើងកុនទាំងអស់គ្នា ។

6- សប្បាយនិងសំដី ,សប្បាយនិងបុគ្គល ។ ឯអ្នកដើងវត្តនិងគណកម្មការ ក៏ប្រឹងរួសរាយ ,រាក់ទាក់ ទទួលភ្ញៀវ ដោយកាយវាចា ,មិនមានពាក្យ ចាក់រុក , ដុកដាន់ , ញុះញង់ , ពាក្យមិនពិរោះទៅរកភ្ញៀវ ក៏ទេដែរ ។ ដូច្នេះអ្នកវត្ត កុំឆេវឆាវ និងភ្ញៀវ និងគ្នាឯង ។ ពាក្យសំដីអាក្រក់ ,ភូតភរ ,កុហក,ញុះញង់ , អួតអាង,ឡេមឡឹម ,តាំងខ្លួនចេះ ,ចេះចំណាប់ក្នុងការ ដែលមិនមែន ជាមុខការខ្លួន ទាំងនេះ ជាចរិតអ្នក ខ្វះសីលធ៌ម ។ ថ្ងៃមួយ ជ្រុលសំដី ,អាក្រក់ លើភ្ញៀវ ,យើងបាត់អស់ហើយភ្ញៀវ ។ ពាក្យលោកថា ៖ គុណមួយសំពៅ ទោសមួយចូលទៅ រលាយបាត់អស់ ។ ដល់ថ្ងៃកំណត់,គុណសម្បទ សង្ឃល្អ ខ្លាំង យ៉ាងណា ,ក៏ ភ្ញៀវរត់ចោលវត្តដែរ ។ បាត់អស់មនុស្សមកវត្ត ។ លុយចំណូលក៏ចុះ លុយក៏ខ្សត់ ,ទប់ សោហ៊ុយមិនរួច ,សុំគិតទាំងអស់គ្នា ។ គណកម្មការដូរគ្នាពីរឆ្នាំម្តង ។ តើគួរ សើរើអ្នកដើងវត្ត និងអ្នក ទទួលខុសត្រូវប្រចាំវត្តដែរឬទេ ? ព្រោះមាត់ចាបមាត់ព្រាបឮមិនពិរោះ ។ បើមានមែន,កុំទុកឱ្យ ធ្វើ ស្តេចត្រាញ់ ហើយសុំអ្នកនោះ កែខ្លួន,កែចរិត ឡើង កុំឱ្យគេភ័យខ្លាច ។ កុំតាំងខ្លួនជាមនុស្សមាន ចរិតផ្ទៃល្ហុង កាលគេចាក់ចំ ,ជ័រ ហូរហែង ។ កុំតាំងខ្លួនជាសត្វពស់វែក រត់ពួន ក្នុងទីងងឹត ស្មោកគ្រោក , លាក់ខ្លួនពួនហូប តែគ្នាឯង ។ល។ នេះជាការសប្បាយនិងអសប្បាយ និងពាក្យសំដីព្រមទាំង បុគ្គល ក្នុងវត្ត ។

7- ឥរិយាបថសប្បាយ ។ ឯឥរិយាបថ មានការឈរ ,ដើរ,អង្គុយ ។ វត្តយើងមានតុកៅអី សំរាប់ធ្វើបុណ្យ អង្គុយលេងយក ខ្យល់ ។ កន្លែងសមាធិរៀបចំស្អាត ,សមល្មមតាមបែបបទលក្ខណៈ ។ ភ្លឺស្រឡះ ឬ ល្ងិតតាមចិត្តចង់ ។ គ្មានរុយគ្មានមូស ។ គ្មានសត្វល្អិតមករំខាន ។ សមាធិចំរើនបានល្អ ។ បើសមាធិ មិនចំរើន ,មិនមែនព្រោះកន្លែង, មិនមែនមកពី គ្រូ, គឺ ពិត ជា បុគ្គល មិនចំរើន ដោយ ប្រការផ្សេងៗ ។ ការប្រកាន់ ឥរិយាបថមិនសមប្រកប ជាទំនាស់ធំ ។ អង្គុយចុក ជើងខ្លាំង នាំមក វេទនា និងធ្វើកម្មខ្លួន ព្រោះទ្រាំ ទប់ទល់វេទនា ។ រកធម៌មិនឡើងទេ ។ អង្គុយ រកធ៌ម មិនមែនអង្គុយ រក បង្អែក, ផ្អែកជញ្ជាំង សសរ ...ដេកលក់ឬ ...អង្គុយបែបនេះក៏មិនចំរើនដែរ ។ ខែ ត្រជាក់ ញាក់ ខ្លាំង ណាស់ ។ អង្គុយទ្រាំ ត្រជាក់ ,រឹងខ្លួនដោយ មិនដឹងខ្លួន,មិននឹកគិតថាខ្លួនធ្វើបុណ្យ ។ នេះគឺ ធ្វើបុណ្យ សន្សំយកកម្ម ក្នុងរោង ត្រជាក់ស្រិប ។ សុំជួយដុត កំដៅ រោងបុណ្យផង ។ ត្រជាក់ពេក, អ្នកមកធ្វើបុណ្យឈឺ, ច្បាស់ជាឡើង លែងមកធ្វើបុណ្យទៀតហើយ ។ ភ្ញៀវ ក៏បាត់ វិភាគទានក៏ខ្សត់ ហើយ ក្រក៏មកដាន់ ។ សន្សំក្នុង កំណាញ់ក្រៅតម្រា លាហើយវត្តប្រកបនិងរស់ក្នុងភាពត្រជាក់ខែរងា ។

ទីកន្លែងណា ដែលមានលំនាំ សប្បាយ ទាំង៧លក្ខណៈខាងលើ ច្បាស់ជា ត្រូវខ្នាតទទួលភ្ញៀវ កកកុញមិនខាន ។

សប្បាយណាស់,យើងដើរលេងសប្បាយ, សប្បាយស្រួល ខ្លួន ,ស្រួលគំនិត ,ស្រួល ចិត្ត, ចិត្តរីករាយ ចង់ទៅលេង ហើយ ទៅលេងទៀត ,មិនធុញទ្រាន់ ,មិនទទួលទោស ។ បើមិនសប្បាយគឺ ឈឺហើយ ដោយ ចិត្តមិនជ្រះថ្លា , ចិត្តពិបាក ,កាយក៏ពិបាក ,ខាតបុណ្យ , កំពប់បុណ្យ ,មិនចំរើនធម៌ , ទុក្ខកើតមានព្រោះមិន បាន ដូចបំណង ។ ទីកន្លែងសប្បាយក្លាយជាទីទុក្ខ ព្រោះ កន្លែងខ្វះលក្ខណៈ ណាមួយ ។

វត្តចុះអន់ថយ,ខ្សោយ , ដោយសារអ្វី ?

១-វត្តជាកន្លែង សាធារណៈក៏ពិតមែន តែមាន ព្រះសង្ឃជា មេ កោយ ។ បើមេ ពិត កុំភ្លេចទុកគំរូ ។

២-កុំប្រមើល មើលកំហុស គ្នា, ចោទ ប្រកាន់គ្នា ជាអំពើអកុសល ។

៣-មើលធ្មុះ កញ្ចក់, មើលទោសខ្លួន កុំចោទអ្នក ដ៏ទៃ, កុំសន្សំកម្ម ។

៤-បើល្ងង់ កុំធ្វើចេះ ។

៥-អ្នកចេះ ក៏ កុំភ្លេចថាខ្លួននៅ ល្ងង់ ក្នុងប្រការផ្សេងៗ ។

៦-សុំរក្សាវត្តជាសម្បត្តិរួម , ជួយឱ្យចំរើន , កុំឱ្យវិនាស ។

ម៉្យាងទៀត វត្តជា ៖

1) មជ្ឈមណ្ឌលទទួលមនុស្ស Centre d’Accueil ។

2)*ជាមជ្ឈមណ្ឌលបណ្ដុះ មនុស្ស ឬវប្បដ្ឋាន* centre de pépinière ។

3) *មជ្ឈមណ្ឌលអប់រំមនុស្ស* centre d’éducation ។

4) *មជ្ឈមណ្ឌល លើកតម្កើងមនុស្ស* centre d’élever la qualité humaine ។

*រក្សាវត្តគ្រាន់ និងធ្វើបុណ្យ និងជួបជុំគ្នា មិនខុសទេ ។ សន្សំបុណ្យជា កុសល ជាកំណាប់នៃ សេចក្ដី ល្អ សំរាប់ យើង ផ្ទាល់ខ្លួន, សំរាប់អ្នក ដ៏ទៃ និង យើងទាំងអស់គ្នា ។ នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយជាមួយ ។*

*សរុបសេចក្ដីទៅ, វត្ត ជាសាលារៀន ដើម្បីប្ដូរ និងជួយបន្តការចេះដឹង និងចំណេះធ្វើឱ្យចំរើន, ជាកន្លែងជួបជុំ ពុទ្ធបរិស័ទ ដើម្បីកសាង ចរិយាធម៌ ឱ្យបានល្អ, ជាកន្លែងប្រជុំជន ប្ដូរយោបល់គ្នា ដោយ រីករាយ នឹងផ្ដល់ឱកាស ដ៏ ប្រសើរមួយ ហុច ឱ្យជួប ញាតិមិត្ត ជិតឆ្ងាយ ចែករំលែក ការនឹករលឹក សុខ ទុក្ខ ជាមួយគ្នា ៕*

Références *ឯកសារយោង* : (0) Dico Pali Français ។ (១) *អាវាស, វិសុទ្ធិមគ្គភាគទី១ ទំព័រ១៩៧ សប្បាយនិងអសប្បាយ* ។ (២) *អ្នកឧបត្ថម្ភវត្តពោធិវង្ស ពោធិព្រឹក្ស លេខ៥៧ ទំព័រ ១៩* ។ (៣) *អានិសង្ស សាងសាលា ពោធិព្រឹក្ស លេខ២៦៥ ទំព័រ ៣២* ។ (៤)*សំណង់ ពោធិព្រឹក្ស លេខ២៥៤ ទំព័រ ១១* ។ (៥)*សមាធិ ពោធិព្រឹក្ស លេខ២៦២ ទំព័រ ២១* ។

ខេត ប៊ុនថាក់ណា

ISSN : 1168-6847

Dépôt légal : 2ème semestre 2019

Président du comité : Vénérable NGIN Phén

Responsable de la publication : M. TEP Bounthakna

Secrétaire de la publication : Mme CHAI UNG Daravichet

Membres : – Vénérable PICH Samon

–Mme. DOUC Sétha –Mme Ravie KHIN

–M. CHAI Michel – M. NGY Hok

– M. THONG Phan – M. YI Seng Long

Avec la collaboration des membres et des amis de l'A.S.B.K.

Pagode Bodhivansa – 101 Boulevard de la République – 77420 Champs-sur-Marne

Téléphone : 01 60 06 44 98